# ផលគុណស្កាលែ និង ផលគុណវ៉ិចទ័រ

## សម្រាប់ថ្នាក់ទី ១២




រៀបរៀងដោយ លឹម ផល្គុន និង សែន ពិសិដ្ឋ

រក្សាសិទ្ធិ

**គណៈកម្មការនិពន្ធ និង រៀបរៀង**

**លឹម ផល្គុន    និង    សែន ពិសិដ្ឋ**

**គណៈកម្មការត្រួតពិនិត្យបច្ចេកទេស**

**លោក យ៉ង់ ឆារី**
**លោក លឹម ឆុន**
**លោក អ៊ឹង សំណាង**

**គណៈកម្មការត្រួតពិនិត្យអក្ខរាវិរុទ្ធ**

**លោក លឹម មិត្តសិរ**

**ការិយកុំព្យូទរ័**

**លោក អ៊ឹង សំណាង និង លឹម ផល្គុន**

# អារម្ភកថា

សួស្តីមិត្តអ្នកសិក្សាជាទីស្រឡាញ់រាប់អាន !
សៀវភៅ **ដេរីវេនៃអនុគមន៍ថ្នាក់ទី១២**ដែលលោកអ្នកកំពុងតែកាន់អាននេះ ខ្ញុំបាទបានរៀបចំឡើងសម្រាប់ទុកជាឯកសារសម្រាប់អ្នកសិក្សាដែលមានបំណងចង់យល់ដឹងអំពីមេរៀននេះឲ្យកាន់តែច្បាស់លាស់។
នៅក្នុងសៀវភៅនេះ យើងខ្ញុំបានសង្ខេបមេរៀន អមជាមួយឧទាហរណ៍គំរូដែលអាចឲ្យអ្នកសិក្សាងាយយល់ និង ឆាប់ចងចាំ ហើយព្រមទាំងមានលំហាត់អនុវត្តន៍សម្រាប់អ្នកសិក្សាហ្វឹកហាត់ដោះស្រាយដោយខ្លួនឯង។

យើងខ្ញុំសង្ឃឹមថា សៀវភៅមួយក្បាលនេះ នឹងអាចចូលរួមផ្តល់នូវគំនិត និង វិធីសាស្ត្រថ្មីៗក្នុងការដោះស្រាយលំហាត់លើផ្នែកដេរីវេនៃអនុគមន៍ចំពោះលោកអ្នកសិក្សាជាពុំខានឡើយ ។

ជាទីបញ្ចប់ខ្ញុំបាទសូមជូនពរចំពោះលោកអ្នក សូមមានសុខភាពល្អ មានប្រាជ្ញាឈ្លាសវៃ និង ទទួលបានជោគជ័យក្នុងគ្រប់ភារកិច្ច ។

បាត់ដំបងថ្ងៃទី០៥ កក្កដា ឆ្នាំ២០១២
អ្នកនិពន្ធ និង ស្រាវជ្រាវ

**លឹម ផល្គុន**

Tel :017 768 246
Email: lim_phalkun@ymail.com
Website: www.mathtoday.wordpress.com

ជំពូកទី១

# សង្ខេបរូបមន្តសំខាន់ៗ

## ១-ផលគុណស្កាលែក្នុងលំហ

### 1/កន្សោមផលគុណស្កាលែ

ក-និយមន័យ

ផលគុណស្កាលែរវាងពីរវ៉ិចទ័រ $\vec{u}$ និង $\vec{v}$ ក្នុងលំហាគឺជា

ចំនួនពិតកំណត់ដោយ $\vec{u}.\vec{v} = |\vec{u}|.|\vec{v}|.\cos\varphi$ ។

$\varphi$ ជាមុំផ្គុំឡើងដោយវ៉ិចទ័រ $\vec{u}$ និង $\vec{v}$ ។



## ខ-កន្សោមវិភាគផលគុណស្កាលែ

ក្នុងគោលអរតូណរម៉ាល់នៃលំហ ផលគុណស្កាលែរវាងពីរវ៉ិចទ័ $\vec{u}=(x_1,y_1,z_1)$ និង $\vec{v}=(x_2,y_2,z_2)$ ក្នុងលំហាគឺជាចំនួនពិតកំណត់ដោយ $\vec{u}.\vec{v}=x_1x_2+y_1y_2+z_1z_2$ ។

## គ-ស្កាលែ និង ណមនៃវ៉ិចទ័

បើគេមានវ៉ិចទ័ $\vec{u}=(a,b,c)$ នោះស្កាលែ និង ណមនៃ $\vec{u}$ កំណត់ដោយ $\vec{u}^{\,2}=a^2+b^2+c^2$ និង $|\vec{u}|=\sqrt{a^2+b^2+c^2}$ ។

## ឃ-កូស៊ីនូសនៃមុំរវាងពីរវ៉ិចទ័

កូស៊ីនូសនៃមុំរវាងពីរវ៉ិចទ័ $\vec{u}=(x_1,y_1,z_1)$ និង វ៉ិចទ័ $\vec{v}=(x_2,y_2,z_2)$ ក្នុងលំហាកំណត់ដោយ ៖

$$\cos\varphi=\frac{\vec{u}.\vec{v}}{|\vec{u}|.|\vec{v}|}=\frac{x_1x_2+y_1y_2+z_1z_2}{\sqrt{x_1^2+y_1^2+z_1^2}.\sqrt{x_2^2+y_2^2+z_2^2}}$$ ។

2/លក្ខណះ

ក/ $\vec{u}.\vec{v}=\vec{v}.\vec{u}$

ខ/ $\vec{u}^2=|\vec{u}|^2$

គ/ $\vec{u}.(\vec{v}+\vec{w})=\vec{u}.\vec{v}+\vec{u}.\vec{w}$

ឃ/ $\vec{u}.(\vec{v}-\vec{w})=\vec{u}.\vec{v}-\vec{u}.\vec{w}$

ង/ $\vec{u}.(\lambda\vec{v})=(\lambda\vec{u}).\vec{v}=\lambda(\vec{u}.\vec{v})\ ,\ \lambda\in IR$

3/វ៉ិចទ័រអរតូកូណាល់ និង វ៉ិចទ័រកូលីនេអ៊ែ

ក-វ៉ិចទ័រអរតូកូណាល់

$\vec{u}$ និង $\vec{v}$ ជាពីរវ៉ិចទ័រអរតូកូណាល់គ្នាលុះត្រាតែ $\vec{u}.\vec{v}=0$

បើ $\vec{u}=(x_1,y_1,z_1)$ និង $\vec{v}=(x_2,y_2,z_2)$ នោះគេបាន ៖

$\vec{u}\perp\vec{v}\Leftrightarrow\vec{u}.\vec{v}=x_1x_2+y_1y_2+z_1z_2=0$ ។

ខ- វ៉ិចទ័រកូលីនេអ៊ែ

$\vec{u}$ និង $\vec{v}$ ជាពីរវ៉ិចទ័រកូលីនេអ៊ែគ្នាលុះត្រាតែមានចំនួនពិត

$\lambda$ មួយដែល $\vec{u} = \lambda.\vec{v}$ ។

បើ $\vec{u} = (x_1, y_1, z_1)$ និង $\vec{v} = (x_2, y_2, z_2)$ នោះគេបាន ៖

$$\vec{u} // \vec{v} \Leftrightarrow \begin{cases} x_1 = \lambda x_2 \\ y_1 = \lambda y_2 \\ z_1 = \lambda z_2 \end{cases} \quad \text{ឬ} \quad \frac{x_1}{x_2} = \frac{y_1}{y_2} = \frac{z_1}{z_2}$$ ។

4/សមីការបន្ទាត់ក្នុងលំហ

ក-សមីការប៉ារ៉ាម៉ែត្រ

សមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ (L) កាត់តាមចំណុច

$A(x_A, y_A, z_A)$ និងមានវ៉ិចទ័រប្រាប់ទិស $\vec{u} = (a, b, c)$

កំណត់ដោយ
$$\begin{cases} x = x_A + at \\ y = y_A + bt \\ z = z_A + ct \quad ; t \in IR \end{cases}$$

## ខ-សមីការឆ្លុះ

សមីការឆ្លុះនៃបន្ទាត់ **(L)** កាត់តាមចំណុច $A(x_A, y_A, z_A)$

និងមានវ៉ិចទ័រប្រាប់ទិស $\vec{u} = (a,b,c)$ កំណត់ដោយ ៖

$$(L): \frac{x - x_A}{a} = \frac{y - y_A}{b} = \frac{z - z_A}{c}$$ ។

## 5/សមីការប្លង់ក្នុងលំហ

សមីការ នៃប្លង់ **(P)** កាត់តាមចំណុច $A(x_A, y_A, z_A)$

និងមានវ៉ិចទ័រណរម៉ាល់ $\vec{n} = (a,b,c)$ កំណត់ដោយ ៖

$$(P): a(x - x_A) + b(y - y_A) + c(z - z_A) = 0$$ ។

## 6/សមីការស្វ៊ែក្នុងលំហ

សមីការស្តង់ដានៃស្វ៊ែ**(S)** មានផ្ចិត $I(a,b,c)$ និងកាំ $R$

កំណត់ដោយ $(S): (x-a)^2 + (y-b)^2 + (z-c)^2 = R^2$ ។

7/ចម្ងាយពីចំណុចមួយទៅប្លង់ក្នុងលំហ

ចម្ងាយពីចំណុច $\mathbf{A(x_A, y_A, z_A)}$ ទៅប្លង់ **(P)** មានសមីការ

$\mathbf{ax + by + cz + d = 0}$ កំណត់ដោយ ៖

$$\mathbf{D = \frac{|ax_A + by_A + cz_A + d|}{\sqrt{a^2 + b^2 + c^2}}}$$ ។

## ២-ផលគុណវិចទ័រក្នុងលំហ

1/លំហមានទិសដៅ

គេឲ្យ $\mathbf{(o, \vec{i}, \vec{j}, \vec{k})}$ ជាតម្រុយអរត្តូណរម៉ាល់នៃលំហ ។

គេថា$\mathbf{(o, \vec{i}, \vec{j}, \vec{k})}$ ជាតម្រុយមានទិសដៅវិជ្ជមានកាលណា អ្នកសង្កេតនៅលើកន្លះបន្ទាត់ $\mathbf{(o, \vec{k})}$ ហើយប្រអប់ជើងនៅចំគល់ **O** បែរមុខតៅចំទិសនៃ $\mathbf{\vec{i}}$ ហើយមានវ៉ិចទ័ $\mathbf{\vec{j}}$ នៅខាងឆ្វេងដៃនៃអ្នកសង្កេត ។

## 2/និយមន័យផលគុណនៃពីរវ៉ិចទ័រ

គេឲ្យ $\vec{u}$ និង $\vec{v}$ ជាពីរវ៉ិចទ័រនៃលំហ ។

ផលគុណរវាងពីរវ៉ិចទ័រ $\vec{u}$ និង $\vec{v}$ គឺជាវ៉ិចទ័រ $\vec{u}\times\vec{v}$ ឬ $\vec{u}\wedge\vec{v}$

កំណត់ដោយ $\vec{u}\times\vec{v} = |\vec{u}|.|\vec{v}|.\sin\varphi.\vec{k}$ ។

ដែល $\varphi$ ជាមុំផ្គុំឡើងដោយវ៉ិចទ័រ $\vec{u}$ និង $\vec{v}$ ។

## 3/លក្ខណះនៃផលគុណនៃពីរវ៉ិចទ័រ

ក/ $\vec{u}\times\vec{v} = -(\vec{v}\times\vec{u})$

ខ/ $\vec{u}\times\vec{u} = \vec{O}$

គ/ $(\lambda\vec{u})\times\vec{v} = \vec{u}\times(\lambda\vec{v}) = \lambda(\vec{u}\times\vec{v})$

ឃ/ $\vec{u}\times\vec{O} = \vec{O}\times\vec{u} = \vec{O}$

ង/ $\vec{u}.(\vec{v}\times\vec{w}) = (\vec{u}\times\vec{v}).\vec{w}$

4/កន្សោមផលគុណនៃពីរវ៉ិចទ័រក្នុងគោលអរតូណរម៉ាល់មានទិសដៅវិជ្ជមាន ៖

គេឲ្យ $(o,\vec{i},\vec{j},\vec{k})$ ជាតម្រុយមានទិសដៅវិជ្ជមាន ។

បើ $\vec{u}=(x_1,y_1,z_1)$ និង $\vec{v}=(x_2,y_2,z_2)$ នោះគេបាន ៖

$$\vec{u}\times\vec{v}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ x_1 & y_1 & z_1\\ x_2 & y_2 & z_2\end{vmatrix}$$

5/ផ្ទៃក្រឡាត្រីកោណ និង ប្រលេឡូក្រាម

ក-ផ្ទៃក្រឡាត្រីកោណ

ផ្ទៃក្រឡានៃត្រីកោណ ABC កំណត់ដោយ ៖

$$S_{ABC}=\frac{1}{2}|\overrightarrow{AB}\times\overrightarrow{AC}|=\frac{1}{2}|\overrightarrow{BA}\times\overrightarrow{BC}|=\frac{1}{2}|\overrightarrow{CA}\times\overrightarrow{CB}|$$

ខ-ប្រលេឡូក្រាម

ផ្ទៃក្រឡានៃត្រីកោណ **ABCD** កំណត់ដោយ ៖

$S_{ABCD} = |\overrightarrow{AB} \times \overrightarrow{AD}|$ ។

6/ផលគុណចម្រុះនៃបីវ៉ិចទ័រក្នុងលំហ

ក-និយមន័យ

គេមាន $\vec{u}, \vec{v}$ និង $\vec{w}$ ជាពីរវ៉ិចទ័រនៃលំហ ។

ផលគុណចម្រុះនៃបីវ៉ិចទ័ររៀបតាមលំដាប់ $\vec{u}, \vec{v}$ និង $\vec{w}$

គឺជាចំនួនពិតកំណត់ដោយ $\vec{u}.(\vec{v} \times \vec{w})$ ។

ខ-ទ្រឹស្តីបទ

បើ $\vec{u} = (x_1, y_1, z_1)$ , $\vec{v} = (x_2, y_2, z_2)$ និង $\vec{v} = (x_2, y_2, z_2)$

នោះគេបាន ៖

$$\vec{u}.(\vec{v}\times\vec{w})=\begin{vmatrix} x_1 & y_1 & z_1 \\ x_2 & y_2 & z_2 \\ x_3 & y_3 & z_3 \end{vmatrix}$$ ។

7/មាឌរបស់ប្រលេពីប៉ែត និង មាឌតេត្រាអ៊ែត

ក-មាឌរបស់ប្រលេពីប៉ែត

មាឌរបស់ប្រលេពីប៉ែតដែលសង់លើ $\vec{u}, \vec{v}$ និង $\vec{w}$

កំណត់ដោយ $V=\left|\vec{u}.(\vec{v}\times\vec{w})\right|$ ។

ខ- មាឌតេត្រាអ៊ែត

$$V_{ABCD}=\frac{1}{6}\left|(\overrightarrow{AB}\times\overrightarrow{AC}).\overrightarrow{AD}\right|$$



## 8/ចម្ងាយពីចំណុចមួយទៅបន្ទាត់មួយក្នុងលំហ

*ទ្រឹស្តីបទ* ៖

ចម្ងាយពីចំណុច **Q** ទៅបន្ទាត់ **(L)** កំណត់ដោយ ៖

$$\mathbf{D} = \frac{|\overrightarrow{\mathbf{PQ}} \times \vec{\mathbf{u}}|}{|\vec{\mathbf{u}}|}$$ ។

ដែល $\mathbf{P} \in \mathbf{(L)}$ និង $\vec{\mathbf{u}}$ ជាវ៉ិចទ័រប្រាប់ទិសនៃបន្ទាត់ ។



## ជំពូកទី២

# កម្រងលំហាត់ជ្រើសរើស

១-ក្នុងតម្រុយអរតូណរម៉ាល់ $(o,\vec{i},\vec{j},\vec{k})$ គេមានបីចំណុច $A(-1,2,3)$ $B(0,-1,1)$ និង $C(2,3,5)$ ។

ក–ចូរកំណត់សមីការប្លង់ $(P)$ កាត់តាមចំណុច $A$ ហើយកែងនឹងវ៉ិចទ័រ $\overrightarrow{BC}$ និងសមីការប៉ារ៉ាម៉ែត្របន្ទាត់ $(L)$ កាត់តាមពីរចំណុច $B$ និង $C$ ។

ខ–គណនាកូអរដោនេនៃចំណុចប្រសព្វ $H$ រវាងបន្ទាត់ $(L)$ ជាមួយប្លង់ $(P)$ ។

គ–រកប្រភេទនៃត្រីកោណ $ABC$ រួចគណនាផ្ទៃក្រលានៃ $\Delta ABC$ ។

២-ក្នុងតម្រុយអរតូណាម៉ាល់ $(o,\vec{i},\vec{j},\vec{k})$ គេមានបួនចំណុច $A(4,0,0)$

$B(0,-2,0)$ , $C(0,0,2)$ និង $D(4,2,2)$ ។

ក–បង្ហាញថាចតុកោណ ABCD ជាប្រលេឡូក្រាម ។

ខ–ចូរកំណត់សមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ (BC) និងសមីការនៃប្លង់

កាត់តាមបីចំណុច A,B និង C ។

គ–យក H ជាចំណោលកែងនៃ A លើបន្ទាត់ (BC) ។

រកកូអរដោនេនៃចំណុច H រួចគណនា AH និងផ្ទៃក្រលាប្រលេឡូ

ក្រាម ABCD ។

ឃ–គេមានចំណុច $S(1,6,-6)$ ។ បង្ហាញថាបន្ទាត់ (SA) កែងនឹង

ប្លង់ (ABCD) រួចគណនាមាឌនៃពីរ៉ាមីត SABCD ។

៣-ក្នុងតម្រុយអរតូណាម៉ាល់ $(o,\vec{i},\vec{j},\vec{k})$ គេមានចំណុច $A(1,2,3)$

និងប្លង់ $(\alpha): x+2y-2z-8=0$ ។

ក–កំណត់សមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(\Delta)$ គូសចេញពីចំណុចA ហើយកែងនឹងប្លង់ $(\beta)$ ត្រង់ចំណុច H ។

ខ–គណនាកូអរដោនេនៃចំណុច H និងចំណុច A' ឆ្លុះគ្នានឹង A ធៀបនឹងប្លង់ $(\alpha)$ ។

គ–កំណត់សមីការប្លង់ $(\beta)$ កាត់តាមចំណុច A' ហើយស្របនឹងប្លង់ $(\alpha)$ ខាងលើ ។

៨-គេឲ្យ $(\alpha): 2x+2y+z-9=0$ និង $(\Delta): \begin{cases} x=2-t \\ y=6-4t \\ z=2+t \quad , t\in IR \end{cases}$

ក–រកកូអរដោនេចំណុចប្រសព្វ A រវាងបន្ទាត់ $(\Delta)$និងប្លង់ $(\alpha)$។

ខ–កំណត់រង្វាស់មុំស្រួចរវាងបន្ទាត់ $(\Delta)$ និង ប្លង់ $(\alpha)$ ។

គ–កំណត់សមីការប្លង់ $(\beta)$ កែងនឹងបន្ទាត់ $(\Delta)$ ត្រង់ចំណុច A ។

ឃ–កំណត់សមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ប្រសព្វរវាងប្លង់$(\alpha)$និង$(\beta)$

៥-គេឲ្យប្លង់ $(\alpha): 2x - 2y + z - 1 = 0$ និងស្វ៊ែ $(S)$មានសមីការ

$(S): x^2 + y^2 + z^2 + 2x - 8y - 4z + 12 = 0$ ។

ក–បង្ហាញថាប្លង់ $(\alpha)$ ប៉ះនឹងស្វ៊ែ $(S)$ ត្រង់ចំណុច $A$ មួយ ។

ខ–កំណត់កូអរដោនេនៃចំណុចប៉ះ $A$ ។

គ–កំណត់សមីការបន្ទាត់ $(\Delta)$ កែងនឹងប្លង់$(\alpha)$ ត្រង់ចំណុច $A$ ។

ឃ–ក្រៅពីចំណុច $A$ បន្ទាត់$(\Delta)$ ប្រសព្វស្វ៊ែ $(S)$ត្រង់ចំណុច $B$ មួយទៀត ។ ចូរកំណត់កូអរដោនេចំណុច $B$ រួចកំណត់សមីការនៃប្លង់ $(\beta)$ ដែលប៉ះស្វ៊ែ $(S)$ ត្រង់ $B$ ។

៦-គេឲ្យបន្ទាត់ $(\Delta): \frac{x+4}{3} = \frac{y+2}{3} = \frac{z+3}{4}$ និងស្វ៊ែ $(S)$មានសមីការ

$(S): x^2 + y^2 + z^2 - 2x - 4y - 6z + 5 = 0$ ។

ក–រកកូអរដោនេចំណុច $A$និង $B$ប្រសព្វរវាង $(\Delta)$ និង $(S)$ ។

ខ–រកសមីការប្លង់ $(\alpha)$និង $(\beta)$ដែលប៉ះស្វ៊ែ$(S)$ត្រង់ $A$ និង $B$។

គ–កំណត់សមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(\Delta')$ ជាប្រសព្វរវាងប្លង់

$(\alpha)$ និង $(\beta)$ ខាងលើ ។

៧-គេឲ្យបន្ទាត់ $(d): \frac{x-3}{2}=\frac{y-3}{2}=\frac{z-2}{-1}$ និងស្វ៊ែ $(S)$ មានសមីការ

ទូទៅ $(S): x^2+y^2+z^2-4x+2y-2z-3=0$ ។

ក–កំណត់កូអរដោនេផ្ចិត $I$ និង កាំ $R$ របស់ស្វ៊ែ $(S)$ ។

ខ–តាង $A$ ជាចំណោលកែងនៃ $I$ លើបន្ទាត់ $(d)$ ។ រកកូអរដោនេនៃចំណុច $A$ ។គណនា $IA$ រួចទាញថាបន្ទាត់$(d)$ប៉ះនឹងស្វ៊ែ$(S)$ ។

គ–កំណត់សមីការប្លង់កែងនឹងបន្ទាត់$(d)$ ហើយប៉ះនឹងស្វ៊ែ$(S)$ ។

៨-គេឲ្យបន្ទាត់ $(d): \frac{x+1}{3}=\frac{y-3}{-2}=\frac{z+1}{4}$ និងប្លង់$(\alpha)$ មានសមីការ

$(\alpha): x+2y+2z-10=0$ ។

ក–កំណត់កូអរដោនេចំណុចប្រសព្វ $A$ រវាង$(d)$និងប្លង់$(\alpha)$ ។

ខ–រកសមីការស្វ៊ែកាំ $R=3$ ហើយប៉ះនឹងប្លង់$(\alpha)$ ត្រង់ចំណុច $A$ ។

៩-គេឲ្យប្លង់ពីរ $(\alpha): x+2y+2z-11=0$ និង $(\beta): 2x-2y+z-1=0$

និងបន្ទាត់ $(\Delta): x=3+t\ , y=6-4t\ , z=7-t$ ដែល $t\in IR$

ក–គណនាកូអរដោណេចំណុចប្រសព្វ $A$ និង $B$ រវាងបន្ទាត់ $(\Delta)$

ជាមួយប្លង់ $(\alpha)$ និង $(\beta)$ រៀងគ្នា ។

ខ–យក $C$ ជាចំណុចមានអាប់ស៊ីស $x=1$ ហើយស្ថិតនៅក្នុងប្លង់

$(\alpha)$ និង $(\beta)$ ។ រកកូអរដោនេនៃចំណុច $C$ រួចរក្រុបភេទនៃ $\Delta ABC$

គ–កំណត់សមីការស្វ៊ែ $(S)$ មានផ្ចិតនៅលើបន្ទាត់ $(\Delta)$ ហើយប៉ះ

រួមទៅនឹងប្លង់ $(\alpha)$ និង $(\beta)$ ។

១០-គេឲ្យបន្ទាត់ពីរ $(d_1)$ និង $(d_2)$ មានសមីការឆ្លុះរៀងគ្នា ៖

$(d_1): \frac{x-5}{-2}=\frac{y-1}{-1}=\frac{z+2}{2}$ និង $(d_2): \frac{x-6}{-4}=\frac{y-2}{-1}=\frac{z-1}{3}$

$A$ ជាចំណុចមួយនៃ $(d_1)$ មានអាប់ស៊ីស $x_A=1$ ហើយ $B$ ជា

ចំណុចមួយនៃ $(d_2)$ មានអាប់ស៊ីស $x_B=t$ ដែល $t\in IR$ ។

ក–ចូរស្រាយថា $AB=\frac{\sqrt{26(t-2)^2+144}}{4}$

ខ–កំណត់តម្លៃ t ដើម្បីឲ្យ (AB) មានតម្លៃអប្បបរមា ។

គ–ចំពោះតម្លៃ t ដែលបានរកឃើញខាងលើ ចូរបង្ហាញថា (AB) ជាបន្ទាត់កែងរួមរវាងបន្ទាត់ $(d_1)$ និង $(d_2)$ រួចទាញរកចម្ងាយរវាងបន្ទាត់$(d_1)$ និង $(d_2)$ ។

១១-គេឲ្យបន្ទាត់ពីរ $(d_1)$ និង $(d_2)$ មានសមីការឆ្លុះរៀងគ្នា ៖

$(d_1): x-2=\frac{y-4}{2}=\frac{z-5}{2}$ និង $(d_2): \frac{x-3}{-1}=y=\frac{z-4}{4}$

ចូររកសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់កែងរួមរវាងបន្ទាត់ $(d_1)$ និង $(d_2)$

១២-នៅក្នុងតម្រុយអរតូណរម៉ាល់មានទិសដៅវិជ្ជមាន $(o,\vec{i},\vec{j},\vec{k})$ គេឲ្យមានចំណុច $A(-1,4,4)\,;B(1,2,3)$ និង $C(3,2,4)$ ។

ក–គណនាផលគុណវ៉ិចទ័រ $\overrightarrow{AB}\times\overrightarrow{AC}$ រួចទាញថាបីចំណុច A,B,C រត់មិនត្រង់គ្នា។ គណនាផ្ទៃក្រឡានៃត្រីកោណ ABC ។

ខ–កំណត់សមីការប្លង់ (ABC) ។

គ–គណនាមាឌនៃចតុមុខ OABC រួចទាញរកចម្ងាយពីចំណុច O

ទៅប្លង់ (ABC) ។

១៣-នៅក្នុងតម្រុយអរតូណម៉ាល់មានទិសដៅវិជ្ជមាន $(o,\vec{i},\vec{j},\vec{k})$

គេឲ្យមានចំណុច $A(0,2,1),B(2,1,-1),C(-4,5,3)$ និង $D(4,6,3)$ ។

ក–ចូរស្រាយថា $\overrightarrow{AB}\times\overrightarrow{AC}=\overrightarrow{AD}$ រួចគណនាផ្ទៃក្រឡានៃ $\Delta ABC$ ។

ខ–កំណត់សមីការប្លង់ (ABC) ។

គ–គណនា $(\overrightarrow{AB}\times\overrightarrow{AC}).\overrightarrow{AD}$ រួចទាញរកមាឌនៃតេត្រាអ៊ែត ABCD ។

ឃ–ទាញរកចម្ងាយពីចំណុច D ទៅប្លង់ (ABC) ។

១៤-នៅក្នុងតម្រុយអរតូណម៉ាល់មានទិសដៅវិជ្ជមាន $(o,\vec{i},\vec{j},\vec{k})$

គេឲ្យមានចំណុច $A(2,2,1),B(3,1,1),C(-2,4,5)$ និង $D(1,-1,0)$ ។

ក–គណនាផលគុណវ៉ិចទ័រ $\overrightarrow{BA}\times\overrightarrow{BC}$ រួចទាញថាបីចំណុច A,B,C

មិនស្ថិតនៅលើបន្ទាត់តែមួយ ។ គណនាផ្ទៃក្រឡានៃ $\Delta ABC$ ។

ខ–កំណត់សមីការប្លង់ (ABC) ។

គ–គណនា$(\overrightarrow{BA}\times\overrightarrow{BC}).\overrightarrow{BD}$ រួចទាញរកមាឌនៃតេត្រាអ៊ែត ABCD ។

ឃ–ទាញរកចម្ងាយពីចំណុច D ទៅប្លង់ (ABC) ។

១៥-គេឲ្យប្លង់(P) កាត់តាម $A(4,-2,2)$ មានវ៉ិចទ័រណរម៉ាល់

$\vec{n}=(1,2,2)$ ហើយបន្ទាត់ $(L):\frac{x-1}{-1}=\frac{y-4}{4}=z-2$ ។

ក-កំណត់សមីការនៃប្លង់(P) រួចគណនាកូអរដោនេចំណុច M

ជាប្រសព្វរវាងបន្ទាត់ (L) និងប្លង់(P) ។

ខ-យក B,C,D ជាប្រសព្វរវាងប្លង់ (P) ជាមួយអក្ស័ (ox),(oy),(oz)

រៀងគ្នាហើយ S ជាប្រសព្វរវាងបន្ទាត់(L) និងអក្ស័(oz) ។

ចូរស្រាយថាចតុកោណ ABCD ជាប្រលេឡូក្រាមរួចគណនាផ្ទៃ

ក្រលារបស់វា ។

គ-បង្ហាញថាបន្ទាត់ (SA) អរត្តូកូណាល់នឹងប្លង់ (ABCD) ។

គណនារង្វាស់ SA រួចទាញរកមាឌនៃពីរ៉ាមីត SABCD ។

១៦-គេឲ្យប្លង់ (P) មានសមីការ $(P): 2x+2y+z-1=0$ និងបន្ទាត់

(L) មានសមីការ $(L): \begin{cases} x = 1-t \\ y = -1-t \\ z = 1+4t \quad , t \in IR \end{cases}$

ក-គណនាកូអរដោនេចំណុចប្រសព្វ M រវាងប្លង់ (P) និងបន្ទាត់ (L)

ខ-យក A ជាចំណុចនៅក្នុងប្លង់ (P) មានអាប់ស៊ីស $x_A = -2$

B និង C ជាប្រសព្វរវាងបន្ទាត់ (L) ជាមួយអក្ស (ox) និង (oy) ។

កំណត់កូអរដោនេ A ដើម្បីឲ្យ ABC ជាត្រីកោណកែងសមបាត

កំពូល A ។ កំណត់សមីការប្លង់ (ABC) ។

១៧-គេឲ្យបន្ទាត់ (L) មានសមីការប៉ារ៉ាម៉ែត្រ

$(L): \begin{cases} x = 2+t \\ y = 4+2t \\ z = 5+2t \ , t \in IR \end{cases}$ និងប្លង់ $(P): x+3y+4z-19=0$ ។

ក-គណនាកូអរដោនេចំណុចប្រសព្វ**M**រវាងប្លង់**(P)**និងបន្ទាត់**(L)**

ខ-រកសមីការប្លង់ **(Q)** កាត់តាមបន្ទាត់**(L)** ហើយកែងនឹងប្លង់**(P)**

៩-ក្នុងតម្រុយអរតូណរម៉ាល់មានទិសដៅវិជ្ជមាន $(o,\vec{i},\vec{j},\vec{k})$

គេមានចំណុច $A(2,1,-1)$ និងប្លង់ពីរ **(P)** និង **(Q)** មាន

សមីការរៀងគ្នា $x+2y+2z-11=0$ និង $3x+y-4z+7=0$

ក-រកសមីការប្លង់**(R)** កាត់តាមចំណុច **A** ហើយកែងរួម

ទៅនឹងប្លង់ពីរ **(P)** និង **(Q)** ។

ខ-រកកូអរដោនេចំណុចប្រសព្វរវាងប្លង់ទាំងបី**(P),(Q),(R)**

គ-យក **C** ជាប្រសព្វរវាងប្លង់**(R)** ជាមួយនឹងអក្ស **(oz)** ។

រកប្រភេទនៃត្រីកោណ **ABC** រួចគណនាផ្ទៃក្រឡារបស់វា

ឃ-រកកូអរដោនេ **D** ដោយដឹងថាចតុកោណ **ABCD**

ជាប្រលេឡូក្រាម ។

ង-តាង**E** ជាចំណុចកណ្តាលនៃ[**AB**] និង **F**ជាចំណុច

កណ្តាលនៃ [**CD**] ។ បង្ហាញថា **EAFC** ជាការេ ។

## ជំពូកទី៣

# ផ្នែកដំណោះស្រាយ

## លំហាត់ទី១

ក្នុងតម្រុយអរតូណាម៉ាល់ $(o,\vec{i},\vec{j},\vec{k})$ គេមានបីចំណុច **A(–1,2,3)** **B(0,–1,1)** និង **C(2,3,5)** ។

ក–ចូរកំណត់សមីការប្លង់ **(P)**កាត់តាមចំណុច **A** ហើយកែងនឹងវ៉ិចទ័រ $\overrightarrow{BC}$ និងសមីការប៉ារ៉ាម៉ែត្របន្ទាត់ **(L)** កាត់តាមពីរចំណុច **B** និង **C** ។

ខ–គណនាកូអរដោនេនៃចំណុចប្រសព្វ **H** រវាងបន្ទាត់ **(L)** ជាមួយប្លង់ **(P)** ។

គ–រកប្រភេទនៃត្រីកោណ **ABC** រួចគណនាផ្ទៃក្រលានៃ **ΔABC** ។

# ដំណោះស្រាយ

ក– កំណត់សមីការប្លង់ (P) និងសមីការប៉ារ៉ាម៉ែត្របន្ទាត់ (L) ៖




វ៉ិចទ័រណរម៉ាល់នៃប្លង់ (P)គឺ $\vec{n} = \overrightarrow{BC} = (2,4,4)$ ។

សមីការប្លង់(P) កាត់តាមចំណុច A អាចសរសេរតាមរូបមន្ត

$$(P): a(x - x_A) + b(y - y_A) + c(z - z_A) = 0$$

$$(P): 2(x + 1) + 4(y - 2) + 4(z - 3) = 0$$

$$(P): 2x + 4y + 4z - 18 = 0$$

$$(P): x + 2y + 2z - 9 = 0$$

ដូចនេះ $(P): x + 2y + 2z - 9 = 0$ ។

វ៉ិចទ័រប្រាប់ទិសនៃបន្ទាត់ (L) គឺ $\vec{u} = \overrightarrow{BC} = (2,4,4)$

សមីការបន្ទាត់ (L) កាត់តាមពីរចំណុច B និង C អាចសរសេរ

តាមរូបមន្ត $(L): \begin{cases} x = x_B + at \\ y = y_B + bt \\ z = z_B + ct \quad , t \in IR \end{cases}$

ដូចនេះ $(L): \begin{cases} x = 2t \\ y = -1 + 4t \\ z = 1 + 4t \quad , t \in IR \end{cases}$

ខ–គណនាកូអរដោនេនៃចំណុចប្រសព្វ H ៖

យកសមីការ (L) ជំនួសក្នុង (P) គេបាន ៖

$2t + 2(-1 + 4t) + 2(1 + 4t) - 9 = 0$

$2t - 2 + 8t + 2 + 8t - 9 = 0$

$18t - 9 = 0$ នាំឲ្យ $t = \frac{1}{2}$ ។

យកតម្លៃ $t = \frac{1}{2}$ ជួសក្នុងសមីការ(L)គេបាន $\begin{cases} x = 1 \\ y = -1 + 2 = 1 \\ z = 1 + 2 = 3 \end{cases}$

ដូចនេះ H(1,1,3) ។

គ-រកប្រភេទនៃត្រីកោណ $\mathbf{ABC}$ រួចគណនាផ្ទៃក្រលានៃ $\Delta\mathbf{ABC}$

គេមាន $\overrightarrow{\mathbf{AB}}=(1,-3,-2)\ ;\ \overrightarrow{\mathbf{BC}}=(2,4,4)\ ;\ \overrightarrow{\mathbf{CA}}=(-3,-1,-2)$

ដោយ $|\overrightarrow{\mathbf{AB}}|=\sqrt{1+9+4}=\sqrt{14}\ ;\ |\overrightarrow{\mathbf{CA}}|=\sqrt{9+1+4}=\sqrt{14}$

នោះគេទាញ $|\overrightarrow{\mathbf{AB}}|=|\overrightarrow{\mathbf{CA}}|=\sqrt{14}$ ។

ដូចនេះ $\mathbf{ABC}$ ជាត្រីកោណសមបាតកំពូល $\mathbf{A}$ ។

ម្យ៉ាងទៀត $\overrightarrow{\mathbf{AH}}=(2,-1,0)$

គេបាន $\overrightarrow{\mathbf{AH}}.\overrightarrow{\mathbf{BC}}=(2)(2)+(-1)(4)+(0)(4)=0$ សមមូល $\overrightarrow{\mathbf{AH}}\perp\overrightarrow{\mathbf{BC}}$

នោះ $\mathbf{AH}$ ជាកម្ពស់នៃ $\Delta\mathbf{ABC}$ ។ គេបាន $\mathbf{S_{ABC}}=\frac{1}{2}\mathbf{AH.BC}$

តែ $\mathbf{AH}=\sqrt{4+1+0}=\sqrt{5}\ ,\mathbf{BC}=\sqrt{4+16+16}=6$

ដូចនេះ $\mathbf{S_{ABC}}=3\sqrt{5}$ (ឯកតាផ្ទៃ)។

# លំហាត់ទី២

ក្នុងតម្រុយអរតូណាម៉ាល់ $(o,\vec{i},\vec{j},\vec{k})$ គេមានបួនចំណុច $A(4,0,0)$ $B(0,-2,0)$ , $C(0,0,2)$ និង $D(4,2,2)$ ។

ក-បង្ហាញថាចតុកោណ **ABCD** ជាប្រលេឡូក្រាម ។

ខ-ចូរកំណត់សមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ **(BC)** និងសមីការនៃប្លង់កាត់តាមបីចំណុច **A,B** និង **C** ។

គ-យក **H** ជាចំណោលកែងនៃ **A** លើបន្ទាត់ **(BC)** ។ រកកូអរដោនេនៃចំណុច **H** រួចគណនា **AH** និងផ្ទៃក្រលាប្រលេឡូក្រាម **ABCD** ។

ឃ-គេមានចំណុច $S(1,6,-6)$ ។ បង្ហាញថាបន្ទាត់ **(SA)** កែងនឹងប្លង់ **(ABCD)** រួចគណនាមាឌនៃពីរ៉ាមីត **SABCD** ។

## ដំណោះស្រាយ

ក-បង្ហាញថាចតុកោណ **ABCD** ជាប្រលេឡូក្រាម

គេមាន $\overrightarrow{AD}=(0,2,2)$ និង $\overrightarrow{BC}=(0,2,2)$

ដោយ $\overrightarrow{AD}=\overrightarrow{BC}$ នោះ **ABCD** ជាប្រលេឡូក្រាម ។

ខ-កំណត់សមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ **(BC)**៖

បន្ទាត់ **(BC)** មានវ៉ិចទ័រប្រាប់ទិស $\overrightarrow{BC}=(0,2,2)$

តាមរូបមន្ត $(BC):\begin{cases} x = x_B + at \\ y = y_B + bt \\ z = z_B + ct \quad , t \in IR \end{cases}$

ដូចនេះ $(BC):\begin{cases} x = 0 \\ y = -2 + 2t \\ z = 2t \qquad ,t \in IR \end{cases}$

កំណត់សមីការនៃប្លង់កាត់តាមបីចំណុច **A,B** និង **C** ៖

តាង $(P): ax + by + cz + d = 0$ ជាប្លង់កាត់តាមបីចំណុច **A,B** និង **C**

នោះកូអរដោនេនៃចំណុច **A,B** និង **C** ផ្ទៀងផ្ទាត់សមីការ **(P)**

គេបានប្រពន្ធ័ $\begin{cases} 4a+d=0 \\ -2b+d=0 \\ 2c+d=0 \end{cases}$ នាំឲ្យ $a=-\frac{d}{4}\ ,b=\frac{d}{2},c=-\frac{d}{2}$

យក $a=-\frac{d}{4}\ ,b=\frac{d}{2},c=-\frac{d}{2}$ ជួសក្នុង (P) គេបាន ៖

$-\frac{d}{4}x+\frac{d}{2}y-\frac{d}{2}z+d=0$ ឬ $(P):x-2y+2z-4=0$ ។

គ-រកកូអរដោនេនៃចំណុច H រួចគណនា AH និងផ្ទៃក្រលាប្រលេឡូក្រាម ABCD ៖

តាង $H(x_H,y_H,z_H)$ ។

ដោយ $H\in(BC)$ នោះ $\begin{cases} x_H=0 \\ y_H=-2+2t \quad (1) \\ z_H=2t \end{cases}$

គេបាន $\overrightarrow{AH}=(-4\ ,-2+2t\ ,2t\ )$

ដោយ $\overrightarrow{AH}\perp\overrightarrow{BC}\Leftrightarrow\overrightarrow{AH}.\overrightarrow{BC}=0$

គេបាន $\overrightarrow{AH}.\overrightarrow{BC}=(0)(-4)+2(-2+2t)+2(2t)=0$ នោះ $t=\frac{1}{2}$

យក $t=\frac{1}{2}$ ជួសក្នុង (1) គេបាន $x_H=0, y_H=-2+1=-1$ , $z_H=1$ ។

ដូចនេះ $H(0,-1,1)$ ។

ហើយ $AH=\sqrt{(-4)^2+(-1)^2+1^2}=3\sqrt{2}$ និង $BC=\sqrt{0+4+4}=2\sqrt{2}$

គេបាន $S_{ABCD}=AH.BC=(3\sqrt{2})(2\sqrt{2})=12$ ។

ដូចនេះ $AH=3\sqrt{2}$ , $S_{ABCD}=12$ (ឯកតាផ្ទៃ)។

ឃ- បង្ហាញថាបន្ទាត់ (SA) កែងនឹងប្លង់ (ABCD) ៖



$\overrightarrow{SA}=(3,-6,6)$ , $\overrightarrow{AB}=(-4,-2,0)$ , $\overrightarrow{AD}=(0,2,2)$

គេមាន $\overrightarrow{SA}.\overrightarrow{AB}=-12+12+0=0 \Leftrightarrow \overrightarrow{SA}\perp\overrightarrow{AB}$

ហើយ $\overrightarrow{SA}.\overrightarrow{AD}=0-12+12=0 \Leftrightarrow \overrightarrow{SA}\perp\overrightarrow{AD}$

នោះគេទាញបាន $(SA)\perp(ABCD)$ ។

គណនាមាឌនៃពីរ៉ាមីត SABCD ៖

តាមរូបមន្ត $V_{SABCD}=\frac{1}{3}S_{ABCD}\times SA$ ដោយ $SA=\sqrt{9+36+36}=9$

ដូចនេះ $V_{SABCD}=\frac{1}{3}\times 12\times 9=36$ (ឯកតាមាឌ)។

# លំហាត់ទី៣

ក្នុងតម្រុយអរតូណរម៉ាល់ $(o,\vec{i},\vec{j},\vec{k})$ គេមានចំណុច $A(1,2,3)$

និងប្លង់ $(\alpha): x+2y-2z-8=0$ ។

ក-កំណត់សមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(\Delta)$ គូសចេញពីចំណុច $A$

ហើយកែងនឹងប្លង់ $(\beta)$ ត្រង់ចំណុច $H$ ។

ខ-គណនាកូអរដោនេនៃចំណុច $H$ និងចំណុច $A'$ ឆ្លុះគ្នានឹង $A$

ធៀបនឹងប្លង់ $(\alpha)$ ។

គ-កំណត់សមីការប្លង់ $(\beta)$ កាត់តាមចំណុច $A'$ ហើយស្របនឹង

ប្លង់ $(\alpha)$ ខាងលើ ។

# ដំណោះស្រាយ

ក-កំណត់សមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(\Delta)$ ៖

ប្លង់ $(\alpha): x+2y-2z-8=0$ មានវ៉ិចទ័រណរម៉ាល់ $\vec{n}=(1,2,-2)$ ។

ដោយបន្ទាត់ $(\Delta)\perp(\alpha)$ នោះ $\vec{n}=(1,2,-2)$ ជាវ៉ិចទ័រប្រាប់ទិសនៃ $(\Delta)$

ដូចនេះសមីការបន្ទាត់ $(\Delta)$ កាត់តាម $A(1,2,3)$ សរសេរ ៖

$$(\Delta):\begin{cases} x=1+t \\ y=2+2t \\ z=3-2t \quad ; t\in IR \end{cases}$$

ខ–គណនាកូអរដោនេនៃចំណុច $H$ និងចំណុច $A'$ ឆ្លុះគ្នានឹង $A$ ធៀបនឹងប្លង់ $(\alpha)$ ៖

យកសមីការ $(\Delta)$ ជួសក្នុង $(\alpha)$ គេបាន ៖

$$(1+t)+2(2+2t)-2(3-2t)-8=0$$
$$1+t+4+4t-6+4t-8=0$$
$$9t-9=0$$

គេទាញបាន $t=\frac{9}{9}=1$ យកជួសក្នុងសមីការ $(\Delta)$ គេបាន $H(2,4,1)$ ។ ហើយដោយចំណុច $A'$ ឆ្លុះគ្នានឹង $A$ ធៀបនឹងប្លង់ $(\alpha)$ នោះចំណុច $H$ ជាចំណុចកណ្ដាលនៃ $A$ និង $A'$ ។

គេបាន $x_{A'}=2x_H-x_A=4-1=3$ , $y_{A'}=2y_H-y_A=8-2=6$

និង $z_{A'} = 2z_H - z_A = 2 - 3 = -1$ ។ដូចនេះ $A'(3,6,-1)$ ។

គ-កំណត់សមីការប្លង់ $(\beta)$៖




ដោយ $(\beta)//(\alpha)$ នោះ $\vec{n} = (1, 2, -2)$ ជាវ៉ិចទ័រណរម៉ាល់នៃ $(\beta)$ ។

ដោយ $(\beta)$ កាត់តាមចំណុច $A'(3,6,-1)$ នោះគេបាន ៖

$$(\beta): 1.(x-3) - 2(y-6) + 2(z+1) = 0$$
$$(\beta): x - 3 - 2y + 12 + 2z + 2 = 0$$
$$(\beta): x - 2y + 2z + 11 = 0$$

ដូចនេះ $(\beta): x - 2y + 2z + 11 = 0$ ។

# លំហាត់ទី៤

គេឲ្យ $(\alpha): 2x+2y+z-9=0$ និង $(\Delta): \begin{cases} x=2-t \\ y=6-4t \\ z=2+t \quad , t\in IR \end{cases}$

ក–រកកូអរដោនេចំណុចប្រសព្វ **A** រវាងបន្ទាត់ $(\Delta)$និងប្លង់ $(\alpha)$។

ខ–កំណត់រង្វាស់មុំស្រួចរវាងបន្ទាត់ $(\Delta)$ និង ប្លង់ $(\alpha)$ ។

គ–កំណត់សមីការប្លង់ $(\beta)$ កែងនឹងបន្ទាត់ $(\Delta)$ ត្រង់ចំណុច **A** ។

ឃ–កំណត់សមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ប្រសព្វរវាងប្លង់$(\alpha)$និង$(\beta)$

# ដំណោះស្រាយ

ក–រកកូអរដោនេចំណុចប្រសព្វ **A** រវាងបន្ទាត់ $(\Delta)$និងប្លង់ $(\alpha)$៖

យកសមីការ $(\Delta)$ ជួសក្នុង $(\alpha)$ គេបាន ៖

$$2(2-t)+2(6-4t)+(2+t)-9=0$$
$$4-2t+12-8t+2+t-9=0$$
$$-9t+9=0$$

គេទាញបាន $t=1$ យកជួសក្នុង $(\Delta)$ គេបាន $x=1, y=2, z=3$

ដូចនេះ $A(1,2,3)$ ។

ខ-កំណត់រង្វាស់មុំស្រួចរវាងបន្ទាត់ $(\Delta)$ និង ប្លង់ $(\alpha)$ ៖

តាង $\vec{n}$ និង $\vec{u}$ រៀងគ្នាជាវ៉ិចទ័រ

នរម៉ាល់ និងវ៉ិចទ័រប្រាប់ទិស

នៃប្លង់$(\alpha)$ និងបន្ទាត់$(\Delta)$

ហើយ $\theta$ ជាមុំរវាងវ៉ិចទ័រ

$\vec{n}$ និង $\vec{u}$ ហើយ $\varphi$ ជាមុំរវាង




បន្ទាត់$(\Delta)$និងប្លង់$(\alpha)$ នោះ គេបាន $\varphi = \frac{\pi}{2} - \theta$ ។

គេមាន $\vec{n} = (2,2,1)\,;\,\vec{u} = (-1\,,-4,1)$ ។

$$\cos\theta = \left|\frac{\vec{n}.\vec{u}}{|\vec{n}|.|\vec{u}|}\right| = \left|\frac{-2-8+1}{\sqrt{4+4+1}\sqrt{1+16+1}}\right| = \frac{\sqrt{2}}{2}$$ គេបាន $\theta = \frac{\pi}{4}$

ដូចនេះ $\varphi = \frac{\pi}{2} - \frac{\pi}{4} = \frac{\pi}{4}$ ។

គ-កំណត់សមីការប្លង់ $(\beta)$ កែងនឹងបន្ទាត់ $(\Delta)$ ត្រង់ចំណុច $A$ ៖

ដោយ $(\beta)\perp(\Delta)$ នោះ $\vec{u}=(-1,-4,1)$ ជាវ៉ិចទ័រណរម៉ាល់នៃប្លង់ $(\beta)$

តាមរូបមន្ត $(\beta): a(x-x_0)+b(y-y_0)+c(z-z_0)=0$

ដោយ $A\in(\beta)$ នោះ $(\beta): -(x-1)-4(y-2)+(z-3)=0$

ដូចនេះ $(\beta): -x-4y+z+6=0$ ។

ឃ-កំណត់សមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ប្រសព្វរវាងប្លង់ $(\alpha)$ និង $(\beta)$

យក $z=t\ ,t\in IR$ នោះ $\begin{cases}2x+2y+t-9=0\\ -x-4y+t+6=0\end{cases}$

បន្ទាប់ពីដោះស្រាយគេបាន $x=4-t\ ,\ y=\frac{1}{2}+\frac{1}{2}t$

ដូចនេះ $(d):\begin{cases}x=4-t\\ y=\frac{1}{2}+\frac{1}{2}t\\ z=t \qquad ,t\in IR\end{cases}$

# លំហាត់ទី៥

គេឲ្យប្លង់ $(\alpha): 2x-2y+z-1=0$ និងស្វ៊ែ $(S)$ មានសមីការ

$(S): x^2+y^2+z^2+2x-8y-4z+12=0$ ។

ក-បង្ហាញថាប្លង់ $(\alpha)$ ប៉ះនឹងស្វ៊ែ $(S)$ ត្រង់ចំណុច $A$ មួយ ។

ខ-កំណត់កូអរដោនេនៃចំណុចប៉ះ $A$ ។

គ-កំណត់សមីការបន្ទាត់ $(\Delta)$ កែងនឹងប្លង់$(\alpha)$ ត្រង់ចំណុច $A$ ។

ឃ-ក្រៅពីចំណុច $A$ បន្ទាត់$(\Delta)$ ប្រសព្វស្វ៊ែ $(S)$ត្រង់ចំណុច $B$ មួយទៀត ។ ចូរកំណត់កូអរដោនេចំណុច $B$ រួចកំណត់សមីការនៃប្លង់ $(\beta)$ ដែលប៉ះស្វ៊ែ $(S)$ ត្រង់ $B$ ។

# ដំណោះស្រាយ

ក-បង្ហាញថាប្លង់ $(\alpha)$ ប៉ះនឹងស្វ៊ែ $(S)$ ត្រង់ចំណុច $A$ មួយ ៖

សមីការស្វ៊ែ $(S)$ អាចសរសេរជាទម្រង់ស្តង់ដាដូចខាងក្រោម ៖

$(S):(x+1)^2+(y-4)^2+(z-2)^2=9$ នោះគេទាញបាន $I(-1,4,2)$

ជាផ្ចិត និង $R=3$ ជារង្វាស់កាំរបស់ស្វ៊ែ ។

ចម្ងាយពីចំណុច $I$ ទៅប្លង់ $(\alpha)$ កំណត់ដោយ ៖

$$d(I,\alpha)=\frac{|2x_I-2y_I+z_I-1|}{\sqrt{2^2+(-2)^2+1^2}}=\frac{|-2-8+2-1|}{3}=3$$

ដោយ $d(I,\alpha)=R=3$ នោះប្លង់ $(\alpha)$ ប៉ះនឹងស្វ៊ែ $(S)$ ត្រង់ចំណុចមួយ

ខ–កំណត់កូអរដោនេនៃចំណុចប៉ះ $A$ ៖



តាង $A(x_A,y_A,z_A)$ ជាចំណុចប៉ះដែលត្រូវរក ។

គេមាន $A\in(\alpha)$ នោះ $2x_A-2y_A+z_A-1=0$ (1)

ម្យ៉ាងទៀត $\overrightarrow{IA}//\vec{n}$ នោះ $\overrightarrow{IA}=t.\vec{n}$

ដោយ $\overrightarrow{IA}=(x_A+1,y_A-4,z_A-2)$ និង $\vec{n}=(2,-2,1)$

គេបាន $\begin{cases}x_A+1=2t\\ y_A-4=-2t\\ z_A-2=t\end{cases}$ ឬ $\begin{cases}x_A=2t-1\\ y_A=-2t+4\\ z_A=t+2\end{cases}$ (2)

យកសមីការ (2) ជួសក្នុង (1) គេបាន ៖

$$2(2t-1)-2(-2t+4)+(t+2)-1=0$$
$$4t-2+4t-8+t+2-1=0$$
$$9t-9=0$$

គេទាញបាន $t=1$ យកជំនួសក្នុង(2)គេបាន $x_A=1,y_A=2,z_A=3$

ដូចនេះ $A(1,2,3)$ ។

គ–កំណត់សមីការបន្ទាត់ $(\Delta)$ កែងនឹងប្លង់$(\alpha)$ ត្រង់ចំណុច $A$ ៖

វ៉ិចទ័រប្រាប់ទិសនៃបន្ទាត់$(\Delta)$ជាវ៉ិចទ័រណរម៉ាល់នៃប្លង់$(\alpha)$

នោះគេបាន $\vec{u}=\vec{n}=(2,-2,1)$ ហើយដោយ $A\in(\Delta)$ នោះ

សមីការប៉ារ៉ាម៉ែត្រនៃ $(\Delta)$ អាចសរសេរ ៖

$$(\Delta):\begin{cases}x=1+2t\\ y=2-2t\\ z=3+t\ \ ,\ t\in IR\end{cases}$$ ។

ឃ-កំណត់កូអរដោនេចំណុច $B$ ៖

តាង $B(x_B,y_B,z_B)$ ។ ដោយ $B\in(\Delta)$ នោះ $\begin{cases}x_B=1+2t\\ y_B=2-2t\\ z_B=3+t\end{cases}$ (3)

យក (3) ជំនួសក្នុងសមីការស្វ៊ែដានៃ $(S)$ គេបាន ៖

$$(1+2t+1)^2+(2-2t-4)^2+(3+t-2)^2=9$$
$$(2t+2)^2+(-2t-2)^2+(t+1)^2=9$$
$$4(t+1)^2+4(t+1)^2+(t+1)^2=9$$
$$9(t+1)^2=9$$

គេទាញបាន $t_1=0\ ,\ t_2=-2$ ។

–ចំពោះ $t=0$ នោះតាម(3)គេបាន $x=1,y=2,z=3$ ជាចំណុច $A$

–ចំពោះ $t=-2$ នោះតាម(3)គេបាន $x=-3,y=6,z=1$ ។

ដូចនេះ $B(-3,6,1)$ ។

កំណត់សមីការនៃប្លង់ $(\beta)$ ដែលប៉ះស្វ៊ែ $(S)$ ត្រង់ $B$ ៖

ប្លង់ $(\beta)$ មានវ៉ិចទ័រណរម៉ាល់ $\vec{n}=(2,-2,1)$ ។

ដូចនេះ $(\beta): 2(x+3)-2(y-6)+(z-1)=0$

ឬ $(\beta): 2x-2y+z+17=0$ ។

# លំហាត់ទី៦

គេឲ្យបន្ទាត់ $(\Delta): \frac{x+4}{3} = \frac{y+2}{3} = \frac{z+3}{4}$ និងស្វ៊ែ $(S)$ មានសមីការ

$(S): x^2 + y^2 + z^2 - 2x - 4y - 6z + 5 = 0$ ។

ក–រកកូអរដោនេចំណុច $A$ និង $B$ ប្រសព្វរវាង $(\Delta)$ និង $(S)$ ។

ខ–រកសមីការប្លង់ $(\alpha)$ និង $(\beta)$ ដែលប៉ះស្វ៊ែ $(S)$ ត្រង់ $A$ និង $B$ ។

គ–កំណត់សមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(\Delta')$ ជាប្រសព្វរវាងប្លង់ $(\alpha)$ និង $(\beta)$ ខាងលើ ។

# ដំណោះស្រាយ

ក–រកកូអរដោនេចំណុច $A$ និង $B$ ប្រសព្វរវាង $(\Delta)$ និង $(S)$ ៖

$$\begin{cases} \frac{x+4}{3} = \frac{y+2}{3} = \frac{z+3}{4} & (\Delta) \\ x^2 + y^2 + z^2 - 2x - 4y - 6z + 5 = 0 & (S) \end{cases}$$

តាង $\frac{x+4}{3} = \frac{y+2}{3} = \frac{z+3}{4} = t$ នោះ $\begin{cases} x = 3t - 4 \\ y = 3t - 2 \\ z = 4t - 3 \end{cases} \quad (1)$

យកសមីការ (1) ជួសក្នុងសមីការ (S) គេបាន ៖

$$(3t-4)^2+(3t-2)^2+(4t-3)^2-2(3t-4)-4(3t-2)-6(4t-3)+5=0$$

$$34t^2-102t+68=0$$

គេទាញឫស $t_1=1\ ;\ t_2=2$ ។

–ចំពោះ $t=1$ តាម(1)គេបាន $x=-1, y=1\ , z=1$ ។

–ចំពោះ $t=2$ តាម(2) គេបាន $x=2\ , y=4\ , z=5$ ។

ដូចនេះ $A(-1\ ,1\ ,1)$ និង $B(2\ ,4\ ,5)$ ។

ខ–រកសមីការប្លង់ $(\alpha)$និង $(\beta)$ដែលប៉ះស្វ៊ែ$(S)$ត្រង់ $A$ និង $B$៖

សមីការស្តង់ដានៃស្វ៊ែ $(S)$អាចសរសេរដូចខាងក្រោម ៖

$(S):(x-1)^2+(y-2)^2+(z-3)^2=9$ ។

គេបានកូអរដោនេនៃផ្ចិតស្វ៊ែ $(S)$ គឺ $I(1\ ,2\ ,3)$ ។

វ៉ិចទ័រណរម៉ាល់នៃប្លង់$(\alpha)$និង $(\beta)$ដែលប៉ះស្វ៊ែ$(S)$ត្រង់ $A$ និង $B$គឺ

$\overrightarrow{IA}=(-2,-1,-2)$ និង $\overrightarrow{IB}=(1,2,2)$ ។

សមីការនៃប្លង់ $(\alpha)$ និង $(\beta)$ អាចសរសេរ ៖

$(\alpha): -2(x+1)-(y-1)-2(z-1)=0$ ឬ $(\alpha): 2x+y+2z-1=0$

$(\beta): 1.(x-2)+2(y-4)+2(z-5)=0$ ឬ $(\beta): x+2y+2z-20=0$ ។

គ–រកសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(\Delta')$ ជាប្រសព្វរវាង $(\alpha)$ និង $(\beta)$

គេមាន $\begin{cases} 2x+y+2z-1=0 \\ x+2y+2z-20=0 \end{cases}$

យក $z=t\in IR$ គេបាន $\begin{cases} 2x+y+2t-1=0 \\ x+2y+2t-20=0 \end{cases}$

បន្ទាប់ពីដោះស្រាយគេបាន $\begin{cases} x=-6-\frac{2}{3}t \\ y=13-\frac{2}{3}t \end{cases}$

ដូចនេះ $(\Delta'): \begin{cases} x=-6-\frac{2}{3}t \\ y=13-\frac{2}{3}t \\ z=t \qquad , t\in IR \end{cases}$ ។

# លំហាត់ទី៧

គេឲ្យបន្ទាត់ $(d):\frac{x-3}{2}=\frac{y-3}{2}=\frac{z-2}{-1}$ និងស្វ៊ែ $(S)$ មានសមីការទូទៅ $(S): x^2+y^2+z^2-4x+2y-2z-3=0$ ។

ក-កំណត់កូអរដោនេផ្ចិត $I$ និង កាំ $R$ របស់ស្វ៊ែ $(S)$ ។

ខ-តាង $A$ ជាចំណោលកែងនៃ $I$ លើបន្ទាត់ $(d)$ ។ រកកូអរដោនេនៃចំណុច $A$ ។គណនា $IA$ រួចទាញថាបន្ទាត់ $(d)$ ប៉ះនឹងស្វ៊ែ $(S)$ ។

គ-កំណត់សមីការប្លង់កែងនឹងបន្ទាត់ $(d)$ ហើយប៉ះនឹងស្វ៊ែ $(S)$ ។

# ដំណោះស្រាយ

ក-កំណត់កូអរដោនេផ្ចិត $I$ និង កាំ $R$ របស់ស្វ៊ែ $(S)$ ៖

សមីការ $(S): x^2+y^2+z^2-4x+2y-2z-3=0$ អាចសរសេរ ៖

$(S):(x-2)^2+(y+1)^2+(z-1)^2=9$ ។

ដូចនេះកូអរដោនេនៃផ្ចិតស្វ៊ែគឺ $I(2,-1,1)$ និងកាំ $R=3$ ។

ខ- រកកូអរដោនេនៃចំណុច A ៖

តាង $A(x_A, y_A, z_A)$ ។

ដោយ $A \in (d)$ នោះកូអរដោនេ A ផ្ទៀងផ្ទាត់សមីការ (d) ។

គេបាន $\frac{x_A - 3}{2} = \frac{y_A - 3}{2} = \frac{z_A - 2}{-1} = t$ នោះ $\begin{cases} x_A = 3 + 2t \\ y_A = 3 + 2t \quad (1) \\ z_A = 2 - t \end{cases}$

គេមាន $\overrightarrow{IA} = (1 + 2t \,, 4 + 2t \,, 1 - t)$ ។

បន្ទាត់ (d) មានវ៉ិចទ័រប្រាប់ទិស $\vec{u} = (2, 2, -1)$ ។

ដោយ $\overrightarrow{IA} \perp \vec{u} \Leftrightarrow \overrightarrow{IA} . \vec{u} = 0$

គេបាន $2(1 + 2t) + 2(4 + 2t) - (1 - t) = 0$

$$2 + 4t + 8 + 4t - 1 + t = 0$$

$$9t + 9 = 0$$

គេទាញ $t = -1$ យកជំនួសក្នុង(1)គេបាន $x_A = 1, y_A = 1 \,, z_A = 3$ ។

ដូចនេះ $A(1,1,3)$ ។

គណនា $IA$ រួចទាញថាបន្ទាត់$(d)$ប៉ះនឹងស្វ៊ែ$(S)$ ៖

គេបាន $IA=\sqrt{(1-2)^2+(1+1)^2+(3-1)^2}=3$ ។

ដោយ $IA=R=3$ ដូចនេះបន្ទាត់$(d)$ប៉ះនឹងស្វ៊ែ$(S)$ត្រង់ $A$ ។

គ-កំណត់សមីការប្លង់កែងនឹងបន្ទាត់$(d)$ ហើយប៉ះនឹងស្វ៊ែ$(S)$ ៖

តាង $\alpha$ ជាប្លង់កែងនឹងបន្ទាត់ $(d)$ នោះ $\vec{u}=(2,2,-1)$ ជាវ៉ិចទ័រ

នរម៉ាល់នៃប្លង់ $\alpha$ ។ សមីការប្លង់ $\alpha$ អាចសរសេរ

$(\alpha): 2x+2y-z+d=0$ ។ ដោយប្លង់ $\alpha$ ប៉ះនឹងស្វ៊ែ $(S)$ នោះគេបាន

$$d(I,\alpha)=R=3$$

$$\frac{|4-2-1+d|}{\sqrt{2^2+2^2+(-1)^2}}=3$$

$$|1+d|=9$$

គេទាញបាន $d_1=8$ ឬ $d_2=-10$ ។

ដូចនេះសមីការប្លង់ដែលត្រូវរកគឺ ៖ $(\alpha_1): 2x+2y-z+8=0$ និង

$(\alpha_2): 2x+2y-z-10=0$ ។

# លំហាត់ទី៨

គេឲ្យបន្ទាត់ $(d): \frac{x+1}{3} = \frac{y-3}{-2} = \frac{z+1}{4}$ និងប្លង់$(\alpha)$ មានសមីការ

$(\alpha): x + 2y + 2z - 10 = 0$ ។

ក–កំណត់កូអរដោនេចំណុចប្រសព្វ $A$ រវាង$(d)$និងប្លង់$(\alpha)$ ។

ខ–រកសមីការស្វ៊ែកាំ$R = 3$ ហើយប៉ះនឹងប្លង់$(\alpha)$ ត្រង់ចំណុច $A$ ។

# ដំណោះស្រាយ

ក–កំណត់កូអរដោនេចំណុចប្រសព្វ $A$ រវាង$(d)$និងប្លង់$(\alpha)$

$$\begin{cases} \frac{x+1}{3} = \frac{y-3}{-2} = \frac{z+1}{4} & (d) \\ x + 2y + 2z - 10 = 0 & (\alpha) \end{cases}$$

តាង $\frac{x+1}{3} = \frac{y-3}{-2} = \frac{z+1}{4} = t$ នោះ $\begin{cases} x = 3t - 1 \\ y = -2t + 3 \quad (1) \\ z = 4t - 1 \end{cases}$

យក (1) ជួសក្នុង $(\alpha)$ គេបាន ៖

$(3t-1)+2(-2t+3)+2(4t-1)-10=0$

$3t-1-4t+6+8t-2-10=0$

$7t-7=0$

គេទាញបាន $t=1$ យកជួសក្នុង (1) គេបាន $x=2, y=1, z=3$

ដូចនេះ $A(2,1,3)$ ។

ខ–រកសមីការស្វ៊ែកាំ $R=3$ ហើយប៉ះនឹងប្លង់ $(\alpha)$ ត្រង់ចំណុច $A$៖

តាង $I(a,b,c)$ ជាផ្ចិតរបស់របស់ស្វ៊ែ (S) ដែលត្រូវរក ។

សមីការស្តង់ដានៃស្វ៊ែអាចសរសេរ ៖

$(S): (x-a)^2+(y-b)^2+(z-c)^2=R^2=9$

ដោយ (S) ប៉ះប្លង់ $(\alpha)$ ត្រង់ $A$ នោះគេបាន $\overrightarrow{AI} // \vec{n}$ ។

គេមាន $\overrightarrow{AI}=(a-2, b-1, c-3)$ និង $\vec{n}=(1,2,2)$ ជាវ៉ិចទ័រណរម៉ាល់

នៃប្លង់ $(\alpha)$ ។

ដោយ $\overrightarrow{AI} // \vec{n}$ នោះ $\overrightarrow{AI}=t.\vec{n}$

គេទាញ $\begin{cases} a-2=t \\ b-1=2t \\ c-3=2t \end{cases}$ ឬ $\begin{cases} a=t+2 \\ b=2t+1 \\ c=2t+3 \end{cases}$ (2)

ហើយ $|\overrightarrow{AI}|=|t|.|\vec{n}|$ នោះ $|t|=\frac{|\overrightarrow{AI}|}{|\vec{n}|}=\frac{R}{|\vec{n}|}=\frac{3}{\sqrt{1+4+4}}=1$

គេទាញ $t_1=-1\,;\,t_2=1$ ។

–ចំពោះ $t=-1$ តាម (2) គេបាន $a=1,b=-1,c=1$

ដូចនេះ $(S_1):(x-1)^2+(y+1)^2+(z-1)^2=9$ ។

–ចំពោះ $t=1$ តាម(2)គេបាន $a=3,b=3,c=5$

ដូចនេះ $(S_2):(x-3)^2+(y-3)^2+(z-5)^2=9$ ។

# លំហាត់ទី៩

គេឲ្យប្លង់ពីរ $(\alpha): x+2y+2z-11=0$ និង $(\beta): 2x-2y+z-1=0$

និងបន្ទាត់ $(\Delta): x=3+t\ , y=6-4t\ , z=7-t$ ដែល $t\in IR$

ក-គណនាកូអរដោណេចំណុចប្រសព្វ $A$ និង $B$ រវាងបន្ទាត់ $(\Delta)$

ជាមួយប្លង់ $(\alpha)$ និង $(\beta)$ រៀងគ្នា ។

ខ-យក $C$ ជាចំណុចមានអាប់ស៊ីស $x=1$ ហើយស្ថិតនៅក្នុងប្លង់

$(\alpha)$ និង $(\beta)$ ។ រកកូអរដោនេនៃចំណុច $C$ រួចរក្រប្រភេទនៃ $\Delta ABC$

គ-កំណត់សមីការស្វ៊ែ $(S)$ មានផ្ចិតនៅលើបន្ទាត់ $(\Delta)$ ហើយប៉ះ

រួមទៅនឹងប្លង់ $(\alpha)$ និង $(\beta)$ ។

# ដំណោះស្រាយ

ក-គណនាកូអរដោណេចំណុចប្រសព្វ $A$ និង $B$ ៖

យកសមីការ $(\Delta)$ ជួសក្នុងសមីការ $(\alpha)$ គេបាន៖

$$(3+t)+2(6-4t)+2(7-t)-11=0$$
$$3+t+12-8t+14-2t-11=0$$
$$-9t+18=0 \Rightarrow t=2$$

យក $t=2$ ជួសក្នុង $(\Delta)$ គេបាន $x=5, y=-2, z=5$ ។

ដូចនេះ $A(5,-2,5)$ ។

យកសមីការ $(\Delta)$ ជួសក្នុងសមីការ $(\beta)$ គេបាន៖

$$2(3+t)-2(6-4t)+(7-t)-1=0$$
$$6+2t-12+8t+7-t-1=0$$
$$9t=0 \Rightarrow t=0$$

យក $t=0$ ជួសក្នុង $(\Delta)$ គេបាន $x=3, y=6, z=7$ ។

ដូចនេះ $B(3,6,7)$ ។

ខ–រកកូអរដោនេនៃចំណុច C រួចរកប្រភេទនៃ $\Delta ABC$

ចំពោះ $x=1$ គេបាន $\begin{cases} 1+2y+2z-11=0 \\ 2-2y+z-1=0 \end{cases}$ ឬ $\begin{cases} 2y+2z-10=0 \\ -2y+z+1=0 \end{cases}$

គេទាញបាន $y=2, z=3$ ។ ដូចនេះ $C(1,2,3)$ ។

គេមាន $\overrightarrow{CA}=(4,-4,2)$ ; $\overrightarrow{CB}=(2,4,4)$

គេបាន $\overrightarrow{CA}.\overrightarrow{CB}=8-16+8=0 \Leftrightarrow \overrightarrow{CA}\perp\overrightarrow{CB}$

ហើយ $|\overrightarrow{CA}|=\sqrt{16+16+4}=6$ ; $|\overrightarrow{CB}|=\sqrt{4+16+16}=6$

គេទាញបាន $CA=CB=6$ ។

ដូចនេះ $ABC$ ជាត្រីកោណកែងសមបាតកំពូល $C$ ។

គ-កំណត់សមីការស្វ៊ែ $(S)$ ៖

តាង $I(a,b,c)$ ជាផ្ចិតរបស់ស្វ៊ែ $(S)$ មានផ្ចិតនៅលើបន្ទាត់ $(\Delta)$

ហើយប៉ះរួមទៅនឹងប្លង់ $(\alpha)$ និង $(\beta)$ ។

គេបាន $\begin{cases} a=3+t \\ b=6-4t \quad (1) \\ c=7-t \end{cases}$

ហើយ $R=d(I,\alpha)=d(I,\beta)$

$$\frac{|(3+t)+2(6-4t)+2(7-t)-11|}{\sqrt{1+4+4}}=\frac{|2(3+t)-2(6-4t)+(7-t)-1|}{\sqrt{4+4+1}}$$

ឬ $\frac{|-9t+18|}{3}=\frac{|9t|}{3}\Rightarrow t=1$ យកជួសក្នុង (1) គេបាន $\begin{cases} a=4 \\ b=2 \\ c=6 \end{cases}$

ហើយ $R=\frac{9}{3}=3$ ។ ដូចនេះសមីការស្តង់ដានៃសមីការស្វ៊ែសរសេរ

$(S):(x-4)^2+(y-2)^2+(z-6)^2=9$ ។

# លំហាត់ទី១០

គេឲ្យបន្ទាត់ពីរ $(d_1)$ និង $(d_2)$ មានសមីការឆ្លុះរៀងគ្នា ៖

$(d_1): \frac{x-5}{-2}=\frac{y-1}{-1}=\frac{z+2}{2}$ និង $(d_2): \frac{x-6}{-4}=\frac{y-2}{-1}=\frac{z-1}{3}$

A ជាចំណុចមួយនៃ $(d_1)$មានអាប់ស៊ីស $x_A=1$ ហើយ B ជាចំណុចមួយនៃ $(d_2)$ មានអាប់ស៊ីស $x_B=t$ ដែល $t\in IR$ ។

ក–ចូរស្រាយថា $AB=\frac{\sqrt{26(t-2)^2+144}}{4}$

ខ–កំណត់តម្លៃ t ដើម្បីឲ្យ (AB) មានតម្លៃអប្បបរមា ។

គ–ចំពោះតម្លៃ t ដែលបានរកឃើញខាងលើ ចូរបង្ហាញថា (AB) ជាបន្ទាត់កែងរួមរវាងបន្ទាត់ $(d_1)$ និង $(d_2)$ រួចទាញរកចម្ងាយរវាងបន្ទាត់$(d_1)$ និង $(d_2)$ ។

# ដំណោះស្រាយ

ក–ស្រាយថា $AB=\frac{\sqrt{26(t-2)^2+144}}{4}$

គេមាន $A\in(d_1)$ ដែល $x_A=1$ នោះ $\frac{1-5}{-2}=\frac{y_A-1}{-1}=\frac{z_A+2}{2}$

គេទាញបាន $y_A=-1\,,z_A=2$ នោះ $A(1,-1\,,2)$ ។

ម្យ៉ាងទៀត $B\in(d_2)$ ដែល $x_B=t$ នោះ $\frac{t-6}{-4}=\frac{y_B-2}{-1}=\frac{z_B-1}{3}$

គេទាញបាន $y_B=\frac{t+2}{4},z_B=\frac{22-3t}{4}$ នោះ $B(\,t\,,\frac{t+2}{4}\,,\frac{22-3t}{4})$ ។

គេបាន $\overrightarrow{AB}=(t-1\;,\frac{t+6}{4}\;,\frac{14-3t}{4}\;)$

ហេតុនេះ $AB=|\overrightarrow{AB}|=\sqrt{(t-1)^2+\frac{(t+6)^2}{16}+\frac{(14-3t)^2}{16}}$

ដូចនេះ $AB=\frac{\sqrt{26t^2-104t+248}}{4}=\frac{\sqrt{26(t-2)^2+144}}{4}$ ។

ខ–កំណត់តម្លៃ t ដើម្បីឲ្យ AB មានតម្លៃអប្បបរមា ៖

គេមាន $AB=\frac{\sqrt{26(t-2)^2+144}}{4}$ (សម្រាយខាងលើ )

ដើម្បីឲ្យ AB មានតម្លៃអប្បបរមាលុះត្រាតែ $t-2=0$ ឬ $t=2$

ដូចនេះ $t=2$ ។

គ– បង្ហាញថា $(AB)$ជាបន្ទាត់កែងរួមរវាងបន្ទាត់ $(d_1)$ និង $(d_2)$ ៖

ចំពោះ $t=2$ គេបាន $B(2\,,1\,,4)$ និង $\overrightarrow{AB}=(1\,,2\,,2)$ ។

តាង $\vec{u}$ និង $\vec{v}$ ជាវ៉ិចទ័រប្រាប់ទិសនៃបន្ទាត់ $(d_1)$ និង $(d_2)$ ។

គេបាន $\vec{u}=(-2\,,-1\,,2)$ និង $\vec{v}=(-4\,,-1\,,3)$ ។

គេមាន $\overrightarrow{AB}.\vec{u}=-2-2+4=0 \Leftrightarrow \overrightarrow{AB}\perp\vec{u}$ ។

ហើយ $\overrightarrow{AB}.\vec{v}=-4-2+6=0 \Leftrightarrow \overrightarrow{AB}\perp\vec{v}$ នោះ $(AB)\perp(d_2)$ ។

ដូចនេះ$(AB)$ជាបន្ទាត់កែងរួមរវាងបន្ទាត់ $(d_1)$ និង $(d_2)$ ។

ទាញរកចម្ងាយរវាងបន្ទាត់$(d_1)$ និង $(d_2)$ ៖

ដោយ $(AB)$ជាបន្ទាត់កែងរួមរវាងបន្ទាត់ $(d_1)$ និង $(d_2)$ នោះ $AB$ ជាចម្ងាយរវាងបន្ទាត់ $(d_1)$ និង $(d_2)$ ។

ដូចនេះ $d(d_1,d_2)=AB=\sqrt{1+4+4}=3$ ។

# លំហាត់ទី១១

គេឲ្យបន្ទាត់ពីរ $(d_1)$ និង $(d_2)$ មានសមីការឆ្លុះរៀងគ្នា ៖

$$(d_1): x-2=\frac{y-4}{2}=\frac{z-5}{2} \quad \text{និង} \quad (d_2): \frac{x-3}{-1}=y=\frac{z-4}{4}$$

ចូររកសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់កែងរួមរវាងបន្ទាត់ $(d_1)$ និង $(d_2)$

# ដំណោះស្រាយ

រកសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់កែងរួមរវាងបន្ទាត់ $(d_1)$ និង $(d_2)$ ៖

តាង $A(x_A, y_A, z_A)\in(d_1)$ និង $B(x_B, y_B, z_B)\in(d_2)$

គេបាន $$\begin{cases} x_A-2=\dfrac{y_A-4}{2}=\dfrac{z_A-5}{2}=p \\ \dfrac{x_B-3}{-1}=y_B=\dfrac{z_B-4}{4}=q \end{cases}$$

នោះ $$\begin{cases} x_A=p+2 \\ y_A=2p+4 \\ z_A=2p+5 \end{cases} \quad (1) \quad \text{និង} \quad \begin{cases} x_B=-q+3 \\ y_B=q \\ z_B=4q+4 \end{cases} \quad (2)$$

គេបាន $\overrightarrow{AB}=(-q-p+1\ , q-2p-4\ , 4q-2p-1\ )$

តាង $\vec{u}$ និង $\vec{v}$ ជាវ៉ិចទ័រប្រាប់ទិសនៃបន្ទាត់ $(d_1)$ និង $(d_2)$ ។

គេបាន $\vec{u}=(1,2,2)$ និង $\vec{v}=(-1,1,4)$ ។

ដើម្បីឲ្យ (AB) ជាបន្ទាត់កែងរួមរវាងបន្ទាត់$(d_1)$ និង $(d_2)$

លុះត្រាតែ $\begin{cases}\overrightarrow{AB}\perp\vec{u}\\\overrightarrow{AB}\perp\vec{v}\end{cases}$ សមមូល $\begin{cases}\overrightarrow{AB}.\vec{u}=0\\\overrightarrow{AB}.\vec{v}=0\end{cases}$

សមមូល $\begin{cases}-q-p+1+2q-4p-8+8q-4p-2=0\\q+p-1+q-2p-4+16q-8p-4=0\end{cases}$

សមមូល $\begin{cases}9q-9p-9=0\\18q-9p-9=0\end{cases}$ នាំឲ្យ $p=-1\,,q=0$ ។

យក $p=-1\,,q=0$ ជួសក្នុង (1) និង (2) គេបាន ៖

$A(1,2,3)$ និង $B(3,0,4)$ ហើយគេបាន $\overrightarrow{AB}=(2,-2,1)$

ដូចនេះ $(AB):\begin{cases}x=1+2t\\y=2-2t\quad;\ t\in IR\\z=3+t\end{cases}$ ។

# លំហាត់ទី១២

នៅក្នុងតម្រុយអរតូណាម៉ាល់មានទិសដៅវិជ្ជមាន $(o,\vec{i},\vec{j},\vec{k})$ មួយ

គេឲ្យមានចំណុច $A(-1,4,4)\,;B(1,2,3)$ និង $C(3,2,4)$ ។

ក–គណនាផលគុណវ៉ិចទ័រ $\overrightarrow{AB}\times\overrightarrow{AC}$ រួចទាញថាបីចំណុច $A,B,C$

រត់មិនត្រង់គ្នា។ គណនាផ្ទៃក្រឡានៃត្រីកោណ $ABC$ ។

ខ–កំណត់សមីការប្លង់ $(ABC)$ ។

គ–គណនាមាឌនៃចតុមុខ $OABC$ រួចទាញរកចម្ងាយពីចំណុច $O$

ទៅប្លង់ $(ABC)$ ។

# ដំណោះស្រាយ

ក–គណនាផលគុណវ៉ិចទ័រ $\overrightarrow{AB}\times\overrightarrow{AC}$ ៖

គេមាន $\overrightarrow{AB}=(2\,,-2\,,-1)$ និង $\overrightarrow{AC}=(4\,,-2\,,0)$

គេបាន $\overrightarrow{AB}\times\overrightarrow{AC}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ 2 & -2 & -1\\ 4 & -2 & 0\end{vmatrix}=-2\vec{i}-4\vec{j}+4\vec{k}$

ដូចនេះ $\overrightarrow{AB}\times\overrightarrow{AC}=(-2,-4,4)$ ។

ទាញថាបីចំណុច $A,B,C$ រត់មិនត្រង់គ្នា៖

ដោយ $\overrightarrow{AB}\times\overrightarrow{AC}\neq\vec{O}$ នោះវ៉ិចទ័រ $\overrightarrow{AB}$ និង $\overrightarrow{AC}$ មិនកូលីនេអ៊ែគ្នា

ដូចនេះ បីចំណុច $A,B,C$ រត់មិនត្រង់គ្នា ។

គណនាផ្ទៃក្រឡានៃត្រីកោណ $ABC$ ៖

តាមរូបមន្ត $S_{ABC}=\frac{1}{2}|\overrightarrow{AB}\times\overrightarrow{AC}|$

ដោយ $\overrightarrow{AB}\times\overrightarrow{AC}=(-2,-4,4)$ នោះ $|\overrightarrow{AB}\times\overrightarrow{AC}|=\sqrt{4+16+16}=6$

ដូចនេះ $S_{ABC}=\frac{1}{2}\times6=3$ (ឯកតាផ្ទៃ) ។

ខ-កំណត់សមីការប្លង់ $(ABC)$ ៖

ប្លង់ $(ABC)$ មានវ៉ិចទ័រណរម៉ាល់ $\vec{n} = \overrightarrow{AB} \times \overrightarrow{AC} = (-2, -4, 4)$

តាមរូបមន្ត $(ABC): a(x - x_A) + b(y - y_A) + c(z - z_A) = 0$

$$-2(x+1) - 4(y-4) + 4(z-4) = 0$$

ដូចនេះ $(ABC): -x - 2y + 2z - 1 = 0$ ។

គ-គណនាមាឌនៃចតុមុខ $OABC$ ៖

តាមរូបមន្ត $V_{OABC} = \frac{1}{6}\left| (\overrightarrow{AB} \times \overrightarrow{AC}).\overrightarrow{AO} \right|$

ដោយ $\overrightarrow{AB} \times \overrightarrow{AC} = (-2, -4, 4)$ និង $\overrightarrow{AO} = (1, -4, -4)$

គេបាន $V_{OABC} = \frac{1}{6}|(-2)(1) + (-4)(-4) + (4)(-4)| = \frac{1}{3}$

ដូចនេះ $V_{OABC} = \frac{1}{3}$ (ឯកតាមាឌ) ។

ទាញរកចម្ងាយពីចំណុច $O$ ទៅប្លង់ $(ABC)$ ៖

តាមរូបមន្ត $V_{OABC} = \frac{1}{3} S_{ABC} \times h$ ដែល $h = d(o, (ABC))$

គេទាញបាន $\mathbf{d(o,(ABC)) = \dfrac{3V_{OABC}}{S_{ABC}} = \dfrac{3\times\frac{1}{3}}{3} = \dfrac{1}{3}}$

ដូចនេះចម្ងាយពី $\mathbf{O}$ ទៅប្លង់ $\mathbf{(ABC)}$ ស្មើនឹង $\mathbf{\frac{1}{3}}$ (ឯកតាប្រវែង) ។

# លំហាត់ទី១៣

នៅក្នុងតម្រុយអរតូណរម៉ាល់មានទិសដៅវិជ្ជមាន $(o,\vec{i},\vec{j},\vec{k})$ មួយ

គេឲ្យមានចំណុច $A(0,2,1),B(2,1,-1),C(-4,5,3)$ និង $D(4,6,3)$ ។

ក-ចូរស្រាយថា $\overrightarrow{AB}\times\overrightarrow{AC}=\overrightarrow{AD}$ រួចគណនាផ្ទៃក្រឡានៃ $\Delta ABC$ ។

ខ-កំណត់សមីការប្លង់ $(ABC)$ ។

គ-គណនា $(\overrightarrow{AB}\times\overrightarrow{AC}).\overrightarrow{AD}$ រួចទាញរកមាឌនៃតេត្រាអ៊ែត $ABCD$ ។

ឃ-ទាញរកចម្ងាយពីចំណុច $D$ ទៅប្លង់ $(ABC)$ ។

# ដំណោះស្រាយ

ក-ស្រាយថា $\overrightarrow{AB}\times\overrightarrow{AC}=\overrightarrow{AD}$ រួចគណនាផ្ទៃក្រឡានៃ $\Delta ABC$ ៖

គេមាន $\overrightarrow{AB}=(2,-1,-2)$ , $\overrightarrow{AC}=(-4,3,2)$ និង $\overrightarrow{AD}=(4,4,2)$

គេបាន $\overrightarrow{AB}\times\overrightarrow{AC}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ 2 & -1 & -2\\ -4 & 3 & 2\end{vmatrix}=4\vec{i}+4\vec{j}+2\vec{k}$

ដូចនេះ $\overrightarrow{AB}\times\overrightarrow{AC}=\overrightarrow{AD}=(4,4,2)$ ។

ខ–កំណត់សមីការប្លង់ $(ABC)$ ៖

ប្លង់ $(ABC)$ មានវ៉ិចទ័រណរម៉ាល់ $\vec{n}=\overrightarrow{AB}\times\overrightarrow{AC}=(4,4,2)$

តាមរូបមន្ត $(ABC): a(x-x_A)+b(y-y_A)+c(z-z_A)=0$

$$4(x-0)+4(y-2)+2(z-1)=0$$

ដូចនេះ $(ABC): 2x+2y+z-5=0$ ។

គ–គណនា $(\overrightarrow{AB}\times\overrightarrow{AC}).\overrightarrow{AD}$ រួចទាញរកមាឌនៃតេត្រាអ៊ែត $ABCD$ ៖

គេមាន $\overrightarrow{AB}\times\overrightarrow{AC}=\overrightarrow{AD}$ (តាមសម្រាយខាងលើ )

ដូចនេះ $(\overrightarrow{AB}\times\overrightarrow{AC}).\overrightarrow{AD}=|\overrightarrow{AD}|^2=16+16+4=36$ ។

តាមរូបមន្ត $V_{ABCD}=\frac{1}{6}\left|(\overrightarrow{AB}\times\overrightarrow{AC}).\overrightarrow{AD}\right|=\frac{1}{6}\times36=6$ (ឯកតាមាឌ) ។

ដូចនេះ $V_{ABCD}=6$ (ឯកតាមាឌ) ។

ឃ–ទាញរកចម្ងាយពីចំណុច **D** ទៅប្លង់ **(ABC)** ៖




គេមាន $V_{ABCD} = \frac{1}{3} S_{ABC} \times d(D,(ABC))$

ដែល $d(D,(ABC)) = h$ ជាកម្ពស់នៃតេត្រាអ៊ែតគូសពីកំពូល **D** ។

គេទាញ $d(D,(ABC)) = \frac{3V_{ABCD}}{S_{ABC}} = \frac{3\times 6}{3} = 6$ (ឯកតាប្រវែង) ។

## លំហាត់ទី១៤

នៅក្នុងតម្រុយអរតូណរម៉ាល់មានទិសដៅវិជ្ជមាន $(o,\vec{i},\vec{j},\vec{k})$ មួយ

គេឲ្យមានចំណុច $A(2,2,1),B(3,1,1),C(-2,4,5)$ និង $D(1,-1,0)$ ។

ក-គណនាផលគុណវ៉ិចទ័រ $\overrightarrow{BA}\times\overrightarrow{BC}$ រួចទាញថាបីចំណុច $A,B,C$ មិនស្ថិតនៅលើបន្ទាត់តែមួយ ។ គណនាផ្ទៃក្រឡានៃ $\Delta ABC$ ។

ខ-កំណត់សមីការប្លង់ $(ABC)$ ។

គ-គណនា$(\overrightarrow{BA}\times\overrightarrow{BC}).\overrightarrow{BD}$ រួចទាញរកមាឌនៃតេត្រាអ៊ែត $ABCD$ ។

ឃ-ទាញរកចម្ងាយពីចំណុច $D$ ទៅប្លង់ $(ABC)$ ។

## ដំណោះស្រាយ

ក-គណនាផលគុណវ៉ិចទ័រ $\overrightarrow{BA}\times\overrightarrow{BC}$

គេមាន $\overrightarrow{BA}=(-1,1,0)\ ,\overrightarrow{BC}=(-5,3,4)$

គេបាន $\overrightarrow{BA}\times\overrightarrow{BC}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ -1 & 1 & 0\\ -5 & 3 & 4\end{vmatrix}=4\vec{i}+4\vec{j}+2\vec{k}$

ដូចនេះ $\overrightarrow{BA}\times\overrightarrow{BC}=(4,4,2)$ ។

ដោយ $\overrightarrow{BA}\times\overrightarrow{BC}=(4,4,2)\neq\vec{O}=(0,0,0)$ នោះ $\overrightarrow{BA}$ និង $\overrightarrow{BA}$ ជាវ៉ិចទ័រ

មិនកូលីនេអ៊ែគ្នា ។

ដូចនេះបីចំណុច $A,B,C$ មិនស្ថិតនៅលើបន្ទាត់តែមួយ ។

គណនាផ្ទៃក្រលានៃ $\Delta ABC$ ៖

គេបាន $S_{ABC}=\frac{1}{2}\left|\overrightarrow{BA}\times\overrightarrow{BC}\right|=\frac{1}{2}\sqrt{16+16+4}=3$ (ឯកតាផ្ទៃ) ។

ខ–កំណត់សមីការប្លង់ $(ABC)$ ៖

ប្លង់ $(ABC)$ មានវ៉ិចទ័រណរម៉ាល់ $\vec{n}=\overrightarrow{BA}\times\overrightarrow{BC}=(4,4,2)$

តាមរូបមន្ត $(ABC): a(x-x_A)+b(y-y_A)+c(z-z_A)=0$

$$4(x-2)+4(y-2)+2(z-1)=0$$
$$4x-8+4y-8+2z-2=0$$
$$4x+4y+2z-18=0$$

ដូចនេះ $(ABC): 2x+2y+z-9=0$ ។

គ-គណនា $(\overrightarrow{BA}\times\overrightarrow{BC}).\overrightarrow{BD}$ រួចទាញរកមាឌនៃតេត្រាអ៊ែត $ABCD$ ៖

គេមាន $\overrightarrow{BA}\times\overrightarrow{BC}=(4,4,2)$ និង $\overrightarrow{BD}=(-2\,,-2\,,-1)$

ដូចនេះ $(\overrightarrow{BA}\times\overrightarrow{BC}).\overrightarrow{BD}=-8-8-2=-18$ ។

តាមរូបមន្ត $V_{ABCD}=\frac{1}{6}\left|(\overrightarrow{BA}\times\overrightarrow{BC}).\overrightarrow{BD}\right|$

ដោយ $(\overrightarrow{BA}\times\overrightarrow{BC}).\overrightarrow{BD}=-8-8-2=-18$

$$V_{ABCD}=\frac{1}{6}\left|(\overrightarrow{BA}\times\overrightarrow{BC}).\overrightarrow{BD}\right|=\frac{1}{6}\times|-18|=3$$

ដូចនេះ $V_{ABCD}=3$ (ឯកតាមាឌ) ។

ឃ–ទាញរកចម្ងាយពីចំណុច **D** ទៅប្លង់ **(ABC)** ៖




គេមាន $V_{ABCD}=\frac{1}{3}S_{ABC}\times d(D,(ABC))$

ដែល $d(D,(ABC))=DH=h$ ជាកម្ពស់នៃតេត្រាអ៊ែតគូសពីកំពូល **D**

គេទាញ $d(D,(ABC))=\frac{3V_{ABCD}}{S_{ABC}}=\frac{3\times 3}{3}=3$ (ឯកតាប្រវែង) ។

# លំហាត់ទី១៥

គេឲ្យប្លង់ **(P)** កាត់តាមចំណុច $\mathbf{A(4,-2,2)}$ មានវ៉ិចទ័រណរម៉ាល់ $\vec{\mathbf{n}}=\mathbf{(1,2,2)}$ ហើយបន្ទាត់ $\mathbf{(L)}:\frac{x-1}{-1}=\frac{y-4}{4}=z-2$ ។

ក-កំណត់សមីការនៃប្លង់**(P)** រួចគណនាកូអរដោនេចំណុច **M** ជាប្រសព្វរវាងបន្ទាត់ **(L)** និងប្លង់**(P)** ។

ខ-យក**B,C,D**ជាប្រសព្វរវាងប្លង់ **(P)**ជាមួយអក្ស **(ox),(oy),(oz)** រៀងគ្នា ។ ចូរស្រាយថាចតុកោណ **ABCD** ជាប្រលេឡូក្រាម រួចគណនាផ្ទៃក្រលារបស់វា ។

គ-គេឲ្យ $\mathbf{S(2,-6,-2)}$ ។ បង្ហាញថាបន្ទាត់ **(SA)**អរត្តូកូណាល់នឹងប្លង់ **(ABCD)** ។ គណនារង្វាស់ **SA** រួចទាញរកមាឌនៃពីរ៉ាមីត **SABCD** ។

# ដំណោះស្រាយ

ក-កំណត់សមីការនៃប្លង់$(P)$៖

តាមរូបមន្ត $(P): a(x-x_A)+b(y-y_A)+c(z-z_A)=0$

ដោយ $A(4,-2,2)$ និង $\vec{n}=(1,2,2)$

គេបាន $1.(x-4)+2(y+2)+2(z-2)=0$

$$x-4+2y+4+2z-4=0$$

ដូចនេះ $(P): x+2y+2z-4=0$ ។

គណនាកូអរដោនេចំណុច $M$ ៖

តាង $\frac{x-1}{-1}=\frac{y-4}{4}=z-2=t$ នាំឲ្យ $\begin{cases} x=-t+1 \\ y=4t+4 \\ z=t+2 \end{cases}$ $(1)$

យកសមីការ(1)ជំនួសក្នុង $(P)$ គេបាន ៖

$(-t+1)+2(4t+4)+2(t+2)-4=0$

$$9t+9=0 \Rightarrow t=-1$$

យកតម្លៃ $t=-1$ ជួសក្នុង(1) គេបាន $\begin{cases} x=-(-1)+1=2 \\ y=4(-1)+4=0 \\ z=-1+2=1 \end{cases}$

ដូចនេះ $M(2\,,0\,,1)$ ។

ខ-ស្រាយថាចតុកោណ **ABCD** ជាប្រលេឡូក្រាម ៖

គេមាន $(P): x+2y+2z-4=0$

-បើ $y=0\,,z=0$ គេបាន $x-4=0$ នោះ $x=4$

-បើ $x=0\,,z=0$ គេបាន $2y-4=0$ នោះ $y=2$

-បើ $x=0\,,y=0$ គេបាន $2z-4=0$ នោះ $z=2$

គេបាន $B(4,0,0)\,,C(0,2,0),D(0,0,2)$ ។

ដោយ $A(4,-2,2)$ នោះ $\overrightarrow{AB}=(0,2,-2)$ និង $\overrightarrow{DC}=(0,2,-2)$

ដោយ $\overrightarrow{AB}=\overrightarrow{DC}$ នោះ **ABCD** ជាប្រលេឡូក្រាម ។

គណនាផ្ទៃក្រលានៃ **ABCD** ៖

តាមរូបមន្ត $S_{ABCD} = |\overrightarrow{AB} \times \overrightarrow{AD}|$

ដោយ $\overrightarrow{AB} = (0,2,-2)$ , $\overrightarrow{AD} = (-4,2,0)$

គេបាន $\overrightarrow{AB} \times \overrightarrow{AD} = \begin{vmatrix} \vec{i} & \vec{j} & \vec{k} \\ 0 & 2 & -2 \\ -4 & 2 & 0 \end{vmatrix} = 4\vec{i} + 8\vec{j} + 8\vec{k}$

$S_{ABCD} = \sqrt{4^2 + 8^2 + 8^2} = 12$ (ឯកតាផ្ទៃ) ។

គ-បង្ហាញថាបន្ទាត់ (SA)អរត្វូកូណាល់នឹងប្លង់ (ABCD) ៖

គេមាន $S(2,-6,-2)$ និង $A(4,-2,2)$ , $B(4,0,0)$ ,$C(0,2,0)$

នោះ $\overrightarrow{SA} = (2,4,4)$ , $\overrightarrow{AB} = (0,2,-2)$;$\overrightarrow{AC} = (-4,4,-2)$

គេបាន $\overrightarrow{SA}.\overrightarrow{AB} = 0 + 8 - 8 = 0 \Leftrightarrow \overrightarrow{SA} \perp \overrightarrow{AB}$

ហើយ $\overrightarrow{SA}.\overrightarrow{AC} = -8 + 16 - 8 = 0 \Leftrightarrow \overrightarrow{SA} \perp \overrightarrow{AC}$

ដូចនេះ(SA)អរត្វូកូណាល់នឹងប្លង់ (ABCD) ។

គណនារង្វាស់ SA រួចទាញរកមាឌនៃពីរ៉ាមីត SABCD ៖




គេបាន $SA = |\overrightarrow{SA}| = \sqrt{4+16+16} = 6$ ។

តាមរូបមន្ត $V_{SABCD} = \frac{1}{3} S_{ABCD} \times SA$ ដោយ $\begin{cases} SA = 6 \\ S_{ABCD} = 12 \end{cases}$

ដូចនេះ $V_{SABCD} = \frac{1}{3} \times 6 \times 12 = 24$ (ឯកតាមាឌ) ។

# លំហាត់ទី១៦

ក្នុងតម្រុយអរតូណរម៉ាល់មានទិសដៅវិជ្ជមាន $(o,\vec{i},\vec{j},\vec{k})$

គេមានចំណុច $A(2,1,-1)$ និងប្លង់ពីរ $(P)$ និង $(Q)$ មាន

សមីការរៀងគ្នា $x+2y+2z-11=0$ និង $3x+y-4z+7=0$

ក-រកសមីការប្លង់$(R)$ កាត់តាមចំណុច $A$ ហើយកែងរួម

ទៅនឹងប្លង់ពីរ $(P)$ និង $(Q)$ ។

ខ-រកកូអរដោនេចំណុចប្រសព្វ$B$រវាងប្លង់ទាំងបី$(P),(Q),(R)$

គ-យក $C$ ជាប្រសព្វរវាងប្លង់$(R)$ ជាមួយនឹងអក្ស $(oz)$ ។

រកប្រភេទនៃត្រីកោណ $ABC$ រួចគណនាផ្ទៃក្រឡារបស់វា

ឃ-រកកូអរដោនេ $D$ ដើម្បីឲ្យ $ABCD$ជាប្រលេឡូក្រាម ។

ង-តាង$E$ ជាចំណុចកណ្តាលនៃ$[AB]$ និង $F$ជាចំណុច

កណ្តាលនៃ $[CD]$ ។ បង្ហាញថា $EAFC$ ជាការេ ។

# ដំណោះស្រាយ

ក-រកសមីការប្លង់(R) ៖

តាង $\vec{n}$ ជាវ៉ិចទ័រណរម៉ាល់នៃប្លង់ (R) ។

ប្លង់ $(P): x+2y+2z-11=0$ និង $(Q): 3x+y-4z+7=0$

មានវ៉ិចទ័រណរម៉ាល់រៀងគ្នា $\vec{n_1}=(1,2,2)$ និង $\vec{n_1}=(3,1,-4)$

ដោយ(R) ជាប្លង់កែងរួមទៅនឹងប្លង់ពីរ (P) និង (Q)

នោះគេបាន $\vec{n}=\vec{n_1}\times\vec{n_2}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ 1 & 2 & 2\\ 3 & 1 & -4\end{vmatrix}=-10\vec{i}+10\vec{j}-5\vec{k}$

ដោយ $A(2,1,-1)\in(R)$ នោះសមីការប្លង់ (R) អាចសរសេរ ៖

$$(R): -10(x-2)+10(y-1)-5(z+1)=0$$

$$(R): -10x+20+10y-10-5z-5=0$$

$$(R): -10x+10y-5z+5=0$$

ដូចនេះ $(R): -2x+2y-z+1=0$ ។

ខ-រកកូអរដោនេចំណុចប្រសព្វរ $\mathbf{B}$ វាងប្លង់ទាំងបី $\mathbf{(P),(Q),(R)}$ ៖

គេបានប្រពន្ធ័ $\begin{cases} x+2y+2z-11=0 \\ 3x+y-4z+7=0 \quad AF \perp CD \\ -2x+2y-z+1=0 \end{cases}$

បន្ទាប់ពីដោះស្រាយគេបានចម្លើយ $x=1, y=2, z=3$

ដូចនេះចំណុចប្រសព្វនៃប្លង់ទាំងបីគឺ $B(1,2,3)$ ។

គ-រកប្រភេទនៃត្រីកោណ $\mathbf{ABC}$ រួចគណនាផ្ទៃក្រឡារបស់វា ៖

ដោយ $\mathbf{C}$ ជាប្រសព្វរវាងប្លង់ $\mathbf{(R)}$ ជាមួយនឹងអក្ស័ $\mathbf{(oz)}$ នោះ

$x_c = y_c = 0$ និង $-z_c + 1 = 0$ ឬ $z_c = 1$ នោះ $C(0,0,1)$ ។

គេមាន $\overrightarrow{AB} = (-1,1,4)$ ; $\overrightarrow{AC} = (-2,-1,2)$ និង $\overrightarrow{BC} = (-1,-2,-2)$

គេបាន $|\overrightarrow{AC}| = \sqrt{4+1+4} = 3$ , $|\overrightarrow{BC}| = \sqrt{1+4+4} = 3$ នោះ $AC = BC$

ហើយ $\overrightarrow{AC}.\overrightarrow{BC} = 2+2-4 = 0 \Leftrightarrow \overrightarrow{AC} \perp \overrightarrow{BC}$ ។

ដូចនេះ $\mathbf{ABC}$ ជាត្រីកោណកែងសមបាតកំពូល $\mathbf{C}$ ។

ឃ-រកកូអរដោនេ **D** ដើម្បីឲ្យ **ABCD** ជាប្រលេឡូក្រាម ៖




តាង $\mathbf{D(x_D, y_D, z_D)}$ ។ បើ **ABCD** ជាប្រលេឡូក្រាមនោះគេបាន

$\overrightarrow{\mathbf{AD}} = \overrightarrow{\mathbf{BC}}$ ដោយ $\begin{cases} \overrightarrow{\mathbf{AD}} = (\mathbf{x_D - 2, y_D - 1, z_D + 1}) \\ \overrightarrow{\mathbf{BC}} = (\mathbf{-1, -2, -2}) \end{cases}$

គេបាន $\begin{cases} \mathbf{x_D - 2 = -1} \\ \mathbf{y_D - 1 = -2} \\ \mathbf{z_D + 1 = -2} \end{cases}$ នាំឲ្យ $\mathbf{x_D = 1, y_D = -1, z_D = -3}$ ។

ដូចនេះ $\mathbf{D(1, -1, -3)}$ ។

## លំហាត់ទី១៧

នៅក្នុងតំរុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ ដែលមានទិសដៅវិជ្ជមាន

គេឱ្យ $(L):\frac{x}{2}=\frac{y-1}{-2}=\frac{z+8}{3}$ និង $(P):x-2y-2z-14=0$ ។

ក-គណនាកូអរដោនេចំនុចប្រសព្វ $A$ រវាង $(L)$ និង $(P)$

ខ-រកសមីការប្លង់ $(Q)$ កាត់តាមបន្ទាត់ $(L)$ ហើយកែងនឹងប្លង់ $(P)$

គ-សរសេរប្រព័ន្ធសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(d)$ ដែលជាប្រសព្វ រវាងប្លង់ $(P)$ និង $(Q)$ ។

ឃ-រកសមីការស្វ៊ែកាំ $R=6$ ហើយប៉ះនឹងប្លង់ $(P)$ ត្រង់ចំនុច $A$ ។

## ដំណោះស្រាយ

ក-គណនាកូអរដោនេចំនុចប្រសព្វ $A$ រវាង $(L)$ និង $(P)$

កូអរដោនេនៃចំនុចប្រសព្វ $A$ ជាចំលើយរបស់ប្រព័ន្ធសមីការ ៖

$$\begin{cases}\frac{x}{2}=\frac{y-1}{-2}=\frac{z+8}{3}\\ x-2y-2z-14=0\end{cases}$$

ដោះស្រាយប្រព័ន្ធនេះគេបាន $A(4,-3,-2)$ ។

ខ-សរសេរសមីការប្លង់ $(Q)$ កាត់តាមបន្ទាត់ $(L)$ហើយកែងនឹងប្លង់ $(P)$

យក $M(x,y,z)$ជាចំនុចទូទៅនៃប្លង់ $(Q)$ គេបាន

$\overrightarrow{AM}(x-4, y+3, z+2)$

តាង $\vec{n}_Q$ ជាវ៉ិចទ័រណរម៉ាល់នៃប្លង់ $(Q)$ នោះគេបាន $\vec{n}_Q = \vec{u} \times \overrightarrow{AM}$

ដែល $\vec{u} = (2,-2,3)$ជាវ៉ិចទ័រប្រាប់ទិសនៃបន្ទាត់ $(L)$ ។

គេបាន $\vec{n}_Q = \begin{vmatrix} \vec{i} & \vec{j} & \vec{k} \\ 2 & -2 & 3 \\ x-4 & y+3 & z+2 \end{vmatrix}$

$$\vec{n}_Q = (-2z-3y-1)\vec{i} - (-2z-3x+1)\vec{j} + (2y+2x+1)\vec{k}$$ ។

ម្យ៉ាងទៀតដោយ $(Q)\perp(P)$នាំឱ្យ $\vec{n}_Q \perp \vec{n}_P$ សមមូល $\vec{n}_P . \vec{n}_Q = 0$

គេបាន

$$1.\left(-2z-3y-1\ \right)-2\left(-2z+33x-1\ \right)-2\left(2y+26x-2\right)=0$$

$$-2z-3y-1\ +4z-36x+3\ -4y-24x+4=0$$

$$-1\ x-7y0+2z+2\ =0\ \ 3$$

ដូចនេះ $\left(Q\right):1\ x+70y-2z-2\ =0$ ។

គ-សរសេរប្រព័ន្ធសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $\left(d\right)$

បន្ទាត់$\left(d\right)$ ដែលជាប្រសព្វរវាង $\left(P\right)$និង $\left(Q\right)$មានវ៉ិចទ័រប្រាប់ទិស

$$\vec{u}_d=\vec{n}_P\times\vec{n}_Q$$

ដែល $\vec{n}_P=\left(1,-2,-2\right)$ និង $\vec{n}_Q=\left(1\ ,70,-2\right)$ ។

គេបាន $\vec{u}_d=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ 1 & -2 & -2\\ 1 & 07 & -2\end{vmatrix}=1\ \vec{i}\,8\!+1\ \vec{j}\,8\!+2\ \vec{k}$ ។

យក $N_0\in\left(d\right)$ នាំឱ្យ $N_0\in\left(P\right)$ និង $N_0\in\left(Q\right)$ ។

គេបាន $\begin{cases}x_0-2y_0-2z_0-1\ =40\\ 1\ x_00+7y_0-2z_0-2\ =30\end{cases}$

យកតម្លៃ $x_0 = 0$ នាំឱ្យ $y_0 = 1$ , $z_0 = -8$ ។

គេបាន $N_0(0,1,-8)$ ។

ដូចនេះសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(d)$ អាចសរសេរ ៖

$$(d): \begin{cases} x = 18t \\ y = 1 - 18t \\ z = -8 + 27t \quad , t \in IR \end{cases}$$

## លំហាត់ទី១៨

នៅក្នុងតំរុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ ដែលមានទិសដៅវិជ្ជមាន គេឱ្យប្លង់ពីរ:

$(P): x-2y+z+4=0$ និង $(Q): 2x+3y-2z-1=0$ ។

ក-សរសេរសមីការឆ្លុះនៃបន្ទាត់ $(L)$ ជាប្រសព្វរវាងប្លង់ $(P)$ និង $(Q)$ ។

ខ-ចូរសរសេរសមីការប្លង់ $(R)$ កាត់តាមចំនុច $A(0,6,8)$ហើយកែងរួមទៅនឹងប្លង់

ទាំងពីរ $(P)$ និង $(Q)$ ខាងលើ ។

គ-គណនាកូអរដោនេនៃចំនុចប្រសព្វ $M$ រវាងបន្ទាត់ $(L)$និង ប្លង់ $(R)$ ។

## ដំណោះស្រាយ

ក-សរសេរសមីការឆ្លុះនៃបន្ទាត់ $(L)$ ជាប្រសព្វរវាងប្លង់ $(P)$ និង $(Q)$

ប្លង់ $(P)$ និង $(Q)$ មានវ៉ិចទ័រណរម៉ាល់រៀងគ្នា

$\vec{n}_P=(1,-2,1)$ និង $\vec{n}_Q=(2,3,-2)$ ។

តាង $\vec{u}_L$ ជាចិ៉ទ័រប្រាប់ទិសនៃបន្ទាត់ $(L)$ នោះគេបាន ៖

$$\vec{u}_L=\vec{n}_P\times\vec{n}_Q=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ 1 & -2 & 1\\ 2 & 3 & -2\end{vmatrix}=\vec{i}+4\vec{j}+7\vec{k}$$ ។

យក $M_0(x_0,y_0,z_0)\in(L)$ នាំឱ្យ $M_0\in(P)$ និង $M_0\in(Q)$

គេបាន $\begin{cases}x_0-2y_0+z_0+4=0\\ 2x_0+3y_0-2z_0-1\ =0\end{cases}$

សន្មតយក $z_0=0$ នាំឱ្យគេទាញបាន $x_0=2\ \ ,y_0=3$ ។

ដូចនេះ $M_0(2,3,0)$ ។

ដូចនេះសមីការឆ្លុះនៃបន្ទាត់ $(L)$ អាចសរសេរតាមរូបមន្ត ៈ

$$(L): \frac{x - x_0}{a} = \frac{y - y_0}{b} = \frac{z - z_0}{c}$$

ឬ $(L): \frac{x-2}{1} = \frac{y-3}{4} = \frac{z}{7}$ ។

ខ-សរសេរសមីការប្លង់ $(R)$ ៖

តាង $\vec{n}_R$ ជាវ៉ិចទ័រណរម៉ាល់នៃប្លង់ $(R)$កាត់តាមចំនុច $A(0,6,8)$ ហើយកែងរួម

ទៅនឹងប្លង់ទាំងពីរ $(P)$ និង $(Q)$ ខាងលើ ។

គេមាន $(R) \perp (P)$និង $(R) \perp (Q)$

នាំឱ្យ $\vec{n}_R \perp \vec{n}_P$ និង $\vec{n}_R \perp \vec{n}_Q$ នាំឱ្យ $\vec{n}_R = \vec{n}_P \times \vec{n}_Q$

គេបាន $\vec{n}_R = \vec{n}_P \times \vec{n}_Q = \begin{vmatrix} \vec{i} & \vec{j} & \vec{k} \\ 1 & -2 & 1 \\ 2 & 3 & -2 \end{vmatrix} = \vec{i} + 4\vec{j} + 7\vec{k}$ ។

សមីការប្លង់ $(R)$អាចសរសេរតាមរូបមន្ត ៖

$$(R): a(x - x_A) + b(y - y_A) + c(z - z_A) = 0$$

$$(R): 1.(x-0)+4(y-6)+7(z-8)=0$$

ដូចនេះ $(R): x+4y+7z-8=0$ ។

គ-គណនាកូអរដោនេនៃចំនុចប្រសព្វ $M$ រវាងបន្ទាត់ $(L)$ និង ប្លង់ $(R)$

កូអរដោនេចំនុចចំនុចប្រសព្វ $M$ រវាងបន្ទាត់ $(L)$ និង ប្លង់ $(R)$ ជាចំលើយប្រព័ន្ធសមីការ:

$$\begin{cases} \dfrac{x-2}{1}=\dfrac{y-3}{4}=\dfrac{z}{7} \quad (1) \\ x+4y+7z-8=0 \quad (2) \end{cases}$$

តាង $\dfrac{x-2}{1}=\dfrac{y-3}{4}=\dfrac{z}{7}=t$

នាំឱ្យ $\begin{cases} x=t+2 \\ y=4t+3 \quad (3) \\ z=7t \end{cases}$ យកទៅជួសក្នុងសមីការ (2)

គេបាន $t+2+4(4t+3)+7(7t)-8=0$

នាំឱ្យ $t=1$ យកជួសក្នុង $(3)$ គេបាន $x = 3, y = 7, z = 7$ ។

ដូចនេះ $M(3,7,7)$ ។

# លំហាត់ទី១៩

នៅក្នុងតំរុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ ដែលមានទិសដៅវិជ្ជមាន ។

គេឱ្យបន្ទាត់ $(L): \frac{x+3}{-3}=\frac{y-4}{4}=\frac{z-1}{3}$ និងចំនុច $A(2,-3,4)$ ។

ក-ចូរគណនាចំងាយពីចំនុច $A$ ទៅបន្ទាត់ $(L)$ ។

ខ-ចូរសរសេរសមីការប្លង់កំនត់ដោយបន្ទាត់ $(L)$ និង ចំនុច $A$ ។

គ-សរសេរសមីការប្លង់ $(Q)$ កាត់តាមបន្ទាត់ $(L)$ ហើយកែងនឹងប្លង់ $(P)$ ។

# ដំណោះស្រាយ

ក-គណនាចំងាយពីចំនុច $A$ ទៅបន្ទាត់ $(L)$

បន្ទាត់ $(L): \frac{x+3}{-3}=\frac{y-4}{4}=\frac{z-1}{3}$

ជាបន្ទាត់កាត់តាមចំនុច $M_0(-3,4,1)$ ហើយមាន

វ៉ិចទ័រប្រាប់ទិស $\vec{u}_L(-3,4,3)$ ។

តាមរូបមន្ត $d(A,(L))=\dfrac{\left\|\overrightarrow{AM_0}\times\vec{u}_L\right\|}{\left\|\vec{u}_L\right\|}$ ដោយ $\overrightarrow{AM_0}(-5,7,-3)$

។

គេមាន $\overrightarrow{AM_0}\times\vec{u}_L=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ -5 & 7 & -3\\ -3 & 4 & 3\end{vmatrix}=33\,\vec{i}+24\,\vec{j}+\vec{k}$

គេទាញ $\left\|\overrightarrow{AM_0}\times\vec{u}_L\right\|=\sqrt{(33)^2+(24)^2+1^2}=\sqrt{1666}$

ហើយ $\left\|\vec{u}_L\right\|=\sqrt{9+16+9}=\sqrt{34}$ ។

គេបាន $d(A,(L))=\dfrac{\sqrt{1666}}{\sqrt{34}}=\sqrt{\dfrac{1666}{34}}=\sqrt{49}=7$ ។

ដូចនេះ $d(A,(L))=7$ ( ឯកត្តាប្រវែង ) ។

ខ-សរសេរសមីការប្លង់កំនត់ដោយបន្ទាត់ $(L)$ និង ចំនុច $A$

តាង $\vec{n}_P$ ជាវ៉ិចទ័រណរម៉ាល់នៃប្លង់ $(P)$ គេបាន

$$\vec{n}_P = \vec{u}_L \times \overrightarrow{M_0A}$$

ដោយ $\vec{u}_L(-3,4,3)$ និង $\overrightarrow{M_0A}(5,-7,3)$ គេបាន ៖

$$\vec{n}_P = \begin{vmatrix} \vec{i} & \vec{j} & \vec{k} \\ -3 & 4 & 3 \\ 5 & -7 & 3 \end{vmatrix} = 33\vec{i} + 24\vec{j} + \vec{k}$$ ។

សមីការប្លង់ $(P)$ អាចសរសេរ ៖

$$(P): 33(x-2) + 24(y+3) + (z-4) = 0$$
$$(P): 33x + 24y + z + 2 = 0$$

គ-សរសេរសមីការប្លង់ $(Q)$ កាត់តាមបន្ទាត់ $(L)$ ហើយកែងនឹងប្លង់ $(P)$

តាង $\vec{n}_Q$ ជាវ៉ិចទ័រណរម៉ាល់នៃប្លង់ $(Q)$ កាត់តាមបន្ទាត់ $(L)$ ហើយកែងនឹងប្លង់ $(P)$។

យក $M(x,y,z)$ ជាចំនុចទូទៅនៃប្លង់ $(Q)$ គេបាន

$\vec{n}_Q = \vec{u}_L \times \overrightarrow{M_0M}$ ។

ដោយ $\vec{u}_L(-3,4,3)$ និង $\overrightarrow{M_0M}(x+3, y-4, z-1)$ គេបាន ៖

$$\vec{n}_Q = \begin{vmatrix} \vec{i} & \vec{j} & \vec{k} \\ -3 & 4 & 3 \\ x+3 & y-4 & z-1 \end{vmatrix}$$

$$= (4z-3y+8)\vec{i} - (-3z-3x-1\ )\vec{j} + (-3y-4x)\vec{k}$$

$\vec{n}_Q = (4z-3y+8, 3z+3x+1\ , -3y-4x)$ ។

ដោយ $(Q)\perp(P)$ នាំឱ្យ $\vec{n}_Q \perp \vec{n}_P$ សមមូល $\vec{n}_Q.\vec{n}_P = 0$ គេបាន ៖

$$3\ (4z-3y+8) - 2\ (3z+3x+6) + (-3y-4x) = 0$$

$$1\ \ z - 39\ y + 22\ \ - 6\ z - 4\ x - 2\ \ - 3y - 4x = 0$$

$$-7\ x - 6\ \ y - 6\ z + 20\ \ = 0\ \ \ 0$$

ដូចនេះ $(Q): 3\ x + 58\ y - 31\ z - 60 = 0$ ។

# លំហាត់ទី២០

នៅក្នុងតំរុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ ដែលមានទិសដៅវិជ្ជមាន ។

គេឱ្យបីចំនុច $A(-2,3,4)$ ,$B(-5,7,7)$ និង $C(7,7,3)$ ។

ក-គណនាផលគុណវ៉ិចទ័រ $\vec{n}=\overrightarrow{AB}\times\overrightarrow{AC}$ ។

ទាញថាបីចំនុច $A,B,C$ រត់មិនត្រង់គ្នា ។

ខ-គណនាក្រឡាផ្ទៃត្រីកោណ $ABC$ ។

គ-សរសេរសមីការប្លង់ $(ABC)$ ។

ឃ-គណនាមាឌតេត្រាអ៊ែត $OAB$ ។

## ដំណោះស្រាយ

ក-គណនាផលគុណវ៉ិចទ័រ $\vec{n}=\overrightarrow{AB}\times\overrightarrow{AC}$

គេមាន $\overrightarrow{AB}=(-3,4,3)$ និង $\overrightarrow{AC}=(9,4,-1)$

គេបាន $\vec{n} = \overrightarrow{AC} \times \overrightarrow{AB} = \begin{vmatrix} \vec{i} & \vec{j} & \vec{k} \\ -3 & 4 & 3 \\ 9 & 4 & -1 \end{vmatrix} = -16\,\vec{i} + 24\,\vec{j} - 48\,\vec{k}$

ដោយ $\overrightarrow{AC} \times \overrightarrow{AB} \neq \vec{O}$ នាំឱ្យ $\overrightarrow{AB}$ និង $\overrightarrow{AC}$ ជាវ៉ិចទ័រមិនកូលីនេអ៊ែគ្នា ។

ដូចនេះបីចំនុច $A, B, C$ រត់មិនត្រង់គ្នា ។

ខ-គណនាក្រឡាផ្ទៃត្រីកោណ $ABC$

តាមរូបមន្ត $S_{ABC} = \frac{1}{2}\left\| \overrightarrow{AC} \times \overrightarrow{AB} \right\|$

$$= \frac{1}{2}\sqrt{(-16)^2 + (24)^2 + (-48)^2} = 28$$

ដូចនេះ $S_{ABC} = 28$ ( ឯកត្តាក្រឡាផ្ទៃ)។

គ-សរសេរសមីការប្លង់ $(ABC)$

ប្លង់ $(ABC)$ មានវ៉ិចទ័រណរម៉ាល់

$\vec{n} = \overrightarrow{AB} \times \overrightarrow{AC} = (-12, 6, -4)$ ។

សមីការប្លង់ $(ABC)$ អាចសរសេរ ៖

$(ABC): a(x - x_A) + b(y - y_A) + c(z - z_A) = 0$

$(ABC): -12(x + 2) + 6(y - 3) - 4(z - 4) = 0$

ដូចនេះ $(ABC): 2x - 3y + 6z - 1 = 0$ ។

ឃ-គណនាមាឌតេត្រាអ៊ែត $OABC$

តាមរូបមន្ត $V_{OABC} = \frac{1}{6}\left|\left(\overrightarrow{AB} \times \overrightarrow{AC}\right) \cdot \overrightarrow{AO}\right|$

ដោយ $\overrightarrow{AB} \times \overrightarrow{AC} = (-12, 6, -4)$ និង $\overrightarrow{AO} = (2, -3, -4)$

គេបាន $V_{OABC} = \frac{1}{6}\left|(-12)(2) + (6)(-3) + (-4)(-4)\right| = \frac{4}{3}$

។

ដូចនេះ $V_{OABC} = \frac{4}{3}$ (ឯកត្តាមាឌ ) ។

## លំហាត់ទី២១

នៅក្នុងតំរុយអរតូណរម៉ាល់មានទិសដៅវិជ្ជមាន $(O,\vec{i},\vec{j},\vec{k})$ ។

(គេយកឯកត្តា 1cm នៅលើអក្ស) គេឱ្យបន្ទាត់ពីរ $(L_1)$ និង $(L_2)$

មានសមីការឆ្លុះរៀងគ្នា

$(L_1):\frac{x+5}{9}=\frac{y+4}{4}=\frac{z-3}{-1}$ និង $(L_2):\frac{x+1}{3}=\frac{y-7}{-4}=\frac{z+1}{-3}$ ។

ក-ចូរសរសេរសមីការប្លង់ $(P)$ កាត់តាម $(L_1)$ ហើយស្របនឹង $(L_2)$ ។

ខ-ចូរសរសេរសមីការប្លង់ $(Q)$ កាត់តាម $(L_2)$ ហើយស្របនឹង $(L_1)$ ។

គ-គណនាចំងាយរវាងបន្ទាត់ $(L_1)$ និង $(L_2)$ ។

## ដំណោះស្រាយ

ក-សរសេរសមីការប្លង់ $(P)$ កាត់តាម $(L_1)$ ហើយស្របនឹង $(L_2)$

$$(L_1): \frac{x+5}{9} = \frac{y+4}{4} = \frac{z-3}{-1}$$

ជាបន្ទាត់កាត់តាម $A(-5,-4,3)$ ហើយស្របនឹង $\vec{u}_1(9,4,-1)$

$$(L_2): \frac{x+1}{3} = \frac{y-7}{-4} = \frac{z+1}{-3}$$

ជាបន្ទាត់កាត់តាម $B(-1,7,-1)$ ហើយស្របនឹង $\vec{u}_2(3,-4,-3)$

តាង $\vec{n}_P$ ជាវ៉ិចទ័រណរម៉ាល់នៃប្លង់ $(P)$ កាត់តាម $(L_1)$ ហើយស្រប នឹង $(L_2)$

គេបាន $\vec{n}_P = \vec{u}_1 \times \vec{u}_2 = \begin{vmatrix} \vec{i} & \vec{j} & \vec{k} \\ 9 & 4 & -1 \\ 3 & -4 & -3 \end{vmatrix} = -1\ \vec{i} + 62\ \vec{j} - 44\ \vec{k}$ ។

សមីការប្លង់ $(P)$ កាត់តាម $(L_1)$ ហើយស្របនឹង $(L_2)$ អាចសរសេរ ៖

$$(P): a(x - x_A) + b(y - y_A) + c(z - z_A) = 0$$
$$(P): -1\ (x + 56) + 2\ (y + 44) - 4\ (z - 38) = 0$$

ដូចនេះ $(P): 2x - 3y + 6z - 2 = 0($ ។

ខ-សរសេរសមីការប្លង់ $(Q)$ កាត់តាម $(L_2)$ ហើយស្របនឹង $(L_1)$

តាង $\vec{n}_Q$ ជាវ៉ិចទ័រណរម៉ាល់នៃប្លង់ $(Q)$ កាត់តាម $(L_2)$ ហើយស្របនឹង $(L_1)$

គេបាន $\vec{n}_Q = \vec{u}_1 \times \vec{u}_2 = \vec{n}_P = -1\ \vec{i} + 2\ \vec{j}6 - 4\ \vec{k}4$ ។

សមីការប្លង់ $(Q)$ អាចសរសេរតាមរូបមន្ត ៖

$$(Q): a(x - x_B) + b(y - y_B) + c(z - z_B) = 0$$
$$(Q): -1\ (x + 1 6) + 2\ (y - 7 4) - 4\ (z + 1 8) = 0$$

ដូចនេះ $(Q): 2x - 3y + 6z + 2 = 0!$ ។

គ-គណនាចំងាយរវាងបន្ទាត់ $(L_1)$ និង $(L_2)$

គេមាន $(L_1) \subset (P)$ ហើយ $(L_2) \subset (Q)$ ដែល $(P) // (Q)$

នោះគេទាញបាន $d((L_1)\ (L_2)) = d((P)\ (Q)) = d(A,(Q))$ ( ព្រោះ $A \in (P)$ )

$$d((L_1)\ (L_2)) = \frac{|2x_A - 3y_A + 6z_A + 2|}{\sqrt{2^2 + (-3)^2 + 6^2}}\ \ 9$$

$$d((L_1)\ (L_2)) = \frac{|2(-5) - 3(-4) + 6(3) + 2|}{7} = \frac{94}{7} = \frac{9}{7}$$

## លំហាត់ទី២២

នៅក្នុងតំរុយអរតូណរម៉ាល់មានទិសដៅវិជ្ជមាន$(O,\vec{i},\vec{j},\vec{k})$ មាន
ឯកត្តា $1cm$

នៅលើអក្សរគេអោយប្លង់ $(P): x + 2y + 2z - 6 = 0$ ។

គេតាង $A,B,C$ ជាចំនុចប្រសព្វរវាងប្លង់ $(P)$ជាមួយអក្ស
$(O\ ),(Ox\ ),(Oy\ )$។

ក. កំនត់កូអរដោនេរនៃចំនុច $A,B$ និង $C$រួចសង់ប្លង់$(P)$

ខ.សរសេរសមីការប៉ារ៉ាម៉ែតនៃបន្ទាត់$(L)$កាត់តាមគល់$O$ហើយកែង
នឹងប្លង់

$(P)$ខាងលើ ។

គ. គណនាផលគុណវ៉ិចទ័រ $\overrightarrow{AB}\times\overrightarrow{AC}$ រួចទាញរកក្រឡាផ្ទៃត្រីកោណ **ABC**។

ឃ. គណនាមាឌតេត្រាអែត **OABC** រួចទាញរកចំងាយពីគល់ **O** ទៅប្លង់ $(ABC)$

## ដំណោះស្រាយ

ក. កំនត់កូអរដោនេនៃចំនុច **A,B** និង **C** រួចសង់ប្លង់ $(P)$

គេមាន $(P): x+2y+2z-6=0$

បើ $y=0, z=0$ នាំអោយ $x-6=0$ ឬ $x=6$ ។ គេបាន $A(6,0,0)$ ។

បើ $x=0, z=0$ នាំអោយ $2y-6=0$ ឬ $y=3$ ។ គេបាន $B(0,3,0)$ ។

បើ $x=0, y=0$ នាំអោយ $2z-6=0$ ឬ $z=3$ ។ គេបាន $C(0,0,3)$ ។




ខ.សរសេរសមីការប៉ារ៉ាម៉ែតនៃបន្ទាត់(L)

តាមរូបមន្ត $(L):\begin{cases} x = x_O + a\,t \\ y = y_O + b\,t \\ z = z_O + c\,t\,, t \in \mathbb{R} \end{cases}$

ដោយបន្ទាត់ $(L)$ កែងនឹងប្លង់ $(P): x + 2y + 2z - 6 = 0$

នាំអោយវ៉ិចទ័រណរម៉ាល់នៃប្លង់ជាវ៉ិចទ័រប្រាប់ទិសរបស់បន្ទាត់។

គេបាន $\vec{u}_L = \vec{n}_P = (1,2,2)$ និង $O(0,0,0)$

ដូចនេះ $(L):\begin{cases} x = t \\ y = 2t \\ z = 2t \quad , t \in \mathbb{R} \end{cases}$

គ. គណនាផលគុណវ៉ិចទ័រ $\overrightarrow{AB} \times \overrightarrow{AC}$

គេមាន $\overrightarrow{AB} = (-6,3,0)$ និង $\overrightarrow{AC} = (-6,0,3)$

$$\overrightarrow{AB} \times \overrightarrow{AC} = \begin{vmatrix} \vec{i} & \vec{j} & \vec{k} \\ -6 & 3 & 0 \\ -6 & 0 & 3 \end{vmatrix} = 9\vec{i} + 18\vec{j} + 18\vec{k}$$ ។

ដូចនេះ $\overrightarrow{AB}\times\overrightarrow{AC} = (9,1,18)$ ។

គណនាក្រឡាផ្ទៃត្រីកោណ ABC ៈ

តាមរូបមន្ត ៖ $S_{ABC} = \frac{1}{2}.\left\|\overrightarrow{AB}\times\overrightarrow{AC}\right\|$

$$= \frac{1}{2}.\sqrt{9^2+1^2+18^2} = 10,5\,cm^2$$

ឃ. គណនាមាឌតេត្រាអែត OABC ៈ

តាមរូបមន្ត ៖ $V_{OABC} = \frac{1}{6}.\left|\left(\overrightarrow{AB}\times\overrightarrow{AC}\right).\overrightarrow{AO}\right|$

ដោយ $\overrightarrow{AB}\times\overrightarrow{AC}(9,1,18)$ និង $\overrightarrow{AO}(-6,0,0)$

គេបាន $V_{OABC} = \frac{1}{6}.\left|-54+0+0\right| = 9\,cm^3$

ដូចនេះ $\boxed{V_{OABC} = 9\,cm^3}$ ។

ទាញរកចំងាយពីគល់ O ទៅប្លង់ $(ABC)$ ៈ




គេមាន $V_{OABC} = \frac{1}{3} . S_{ABC} \times d(O;(ABC))$ ដែល $OH = d(O;(ABC))$

គេបាន $d(0,(ABC)) = \frac{3.V_{OABC}}{S_{ABC}} = \frac{3.9}{13,5} = 2cm$ ។

## លំហាត់ទី២៣

គេអោយគូប A B C មួយមានទ្រនុងស្មើ1។

លំហាមានទិសដៅតាមតំរុយអរតូណរម៉ាល់មានទិសដៅវិជ្ជមាន

$\left(A,\overrightarrow{A},\overrightarrow{BA},\overrightarrow{DA}\ E\right)$




គេយក I ជាចំនុចកណ្តាលនៃអង្កត់ [EF] និង K ជាផ្ចិតការេ ADH ។

ក. ចូរផ្ទៀងផ្ទាត់ថា $\overrightarrow{B} = \overrightarrow{KI} \times \overrightarrow{I}$ រួចគណនាក្រឡាផ្ទៃត្រីកោណ IGA ។

ខ. គណនាមាឌតេត្រាអែត ABIG រួចទាញរកចំងាយពីចំនុច B ទៅប្លង់ (AIG)

# ដំណោះស្រាយ

ក-ផ្ទៀងផ្ទាត់ថា $\overrightarrow{B\ \ } = \overrightarrow{KI}\ \&\ \overrightarrow{I\ \ A}$

ក្នុងលំហ $\left(A, \overrightarrow{AB}, \overrightarrow{AD}, \overrightarrow{A\ }\ \right)$

គេមាន ៖

$$A(0,0,0)\ ,B(1,0,0)\ ,C(1,1,0)\ ,D(0,1,0)$$

$$E(0,0,1)\ ,F(1,0,1)\ ,G(1,1,1)\ ,H(0,1,1)$$

ដោយ $I$ ជាចំនុចកណ្តាលនៃអង្កត់ $[EF]$ គេបាន

$$I\left(\frac{0+1}{2},\frac{0+0}{2},\frac{1+1}{2}\right)$$

ឬ $I\left(\frac{1}{2},0,1\right)$ និង $K$ ជាផ្ចិតការេ $ADH$ នោះវាជាចំនុចកណ្តាលនៃអង្កត់ $[AH]$

គេបាន ៖

$K\left(\frac{0+0}{2},\frac{0+1}{2},\frac{0+1}{2}\right)$ ឬ $K\left(0,\frac{1}{2},\frac{1}{2}\right)$ ។

យើងបាន ៖ $\overrightarrow{BK}=\left(-1,\frac{1}{2},\frac{1}{2}\right)$ $(1)$

ហើយ $\overrightarrow{IG}=\left(\frac{1}{2},1,0\right)$ , $\overrightarrow{IA}=\left(-\frac{1}{2},0,-1\right)$ គេបាន ៖

$$\overrightarrow{IG}\times\overrightarrow{IA}=\begin{vmatrix}\overrightarrow{AB} & \overrightarrow{AD} & \overrightarrow{AE}\\ \frac{1}{2} & 1 & 0\\ -\frac{1}{2} & 0 & -1\end{vmatrix}$$

$$\overrightarrow{IG}\times\overrightarrow{IA}=-\overrightarrow{AB}+\frac{1}{2}.\overrightarrow{AD}+\frac{1}{2}.\overrightarrow{AE}$$

គេបាន $\overrightarrow{IG}\times\overrightarrow{IA}=\left(-1,\frac{1}{2},\frac{1}{2}\right)$ $(2)$

តាម $(1)$ និង $(2)$ គេបាន ៖ $\overrightarrow{BK}=\overrightarrow{IG}\times\overrightarrow{IA}$ ។

គណនាក្រឡាផ្ទៃត្រីកោណ **IGA** :

តាមរូបមន្ត ៖ $S_{AIG}=\frac{1}{2}\left\|\overrightarrow{IA}\times\overrightarrow{IG}\right\|=\frac{1}{2}\cdot\left\|\overrightarrow{B}\right\|$

$$=\frac{1}{2}\cdot\sqrt{1+\frac{1}{4}+\frac{1}{4}}=\frac{\sqrt{6}}{4}$$ ឯកតាផ្ទៃ។

ខ. គណនាមាឌតេត្រាអែត $ABIG$ ៖

តាមរូបមន្ត $V_{ABIG}=\frac{1}{6}\left|\left(\overrightarrow{IA}\times\overrightarrow{IG}\right)\cdot\overrightarrow{IB}\right|$

ដោយ $\overrightarrow{IB}=\left(\frac{1}{2},0,-1\right)$ និង $\overrightarrow{IA}\times\overrightarrow{IG}=\left(-1,\frac{1}{2},\frac{1}{2}\right)$

គេបាន ៖ $V_{ABIG}=\frac{1}{6}\cdot\left|-\frac{1}{2}+0-\frac{1}{2}\right|=\frac{1}{6}$ ឯកតាមាឌ ។

រកចំងាយពីចំនុច $B$ ទៅប្លង់ $(AIG)$ ៖

តាមរូបមន្ត ៖ $V_{ABIG}=\frac{1}{3}\cdot S_{AIG}\times d(B,(AIG))$

នាំអោយ $d(B,(AIG))=\frac{3V_{ABIG}}{S_{AIG}}$

ដូចនេះ $d(B,(AIG))=\dfrac{3.\frac{1}{6}}{\frac{\sqrt{6}}{4}}=\dfrac{\sqrt{6}}{3}$ ។

## លំហាត់ទី២៤

ក្នុងតំរុយអរតូណរម៉ាល់ដែលមានទិសដៅវិជ្ជមាន $(0,\vec{i},\vec{j},\vec{k})$ គេអោយចំនុច ៖

$A(0,6,0)$ , $B(0,4,2)$ និង $C(2,0,5)$ ។

ក. ចូរសង់ចតុមុខ $OAB$ ។

ខ. គណនាផលគុណវ៉ិចទ័រ $\overrightarrow{AB}\times\overrightarrow{AC}$ រួចគណនាក្រឡាផ្ទៃត្រីកោណ $ABC$ ។

គ.គណនា $\left(\overrightarrow{OA}\times\overrightarrow{OB}\right)\cdot\overrightarrow{OC}$ រួចទាញរកមាឌនៃចតុមុខ $OAB$ ។

ឃ. ទាញរកចំងាយពីចំនុច $O$ ទៅប្លង់ $(ABC)$ ។

ង.សរសេរសមីការប្លង់$(ABC)$ ។

## ដំណោះស្រាយ

ក. សង់ចតុមុខ $OAB$

$A(0,6,0)$ ,$B(0,4,2)$ និង $C(2,0,5)$



ខ. គណនាផលគុណវ៉ិចទ័រ $\overrightarrow{AB} \times \overrightarrow{AC}$ ៖

គេមាន $\overrightarrow{AB} = (0,2,-2)$ និង $\overrightarrow{AC} = (2,-6,5)$

គេបាន $$\overrightarrow{AB} \times \overrightarrow{AC} = \begin{vmatrix} \vec{i} & \vec{j} & \vec{k} \\ 0 & 2 & -2 \\ 2 & -6 & 5 \end{vmatrix} = -2.\vec{i} - 4.\vec{j} - 4.\vec{k}$$

ដូចនេះ $\overrightarrow{AB} \times \overrightarrow{AC} = (-2,-4,-4)$ ។

គណនាក្រឡាផ្ទៃត្រីកោណ $ABC$ ៖

$$S_{ABC} = \frac{1}{2}\left\|\overrightarrow{AB}\times\overrightarrow{AC}\right\| = \frac{1}{2}.\sqrt{(-2)^2+(-4)^2+(-4)^2} = 3$$ ។

ដូចនេះ $S_{ABC} = 3$ ឯកតាផ្ទៃ ។

គ.គណនា $\left(\overrightarrow{OA}\times\overrightarrow{OB}\right)\overrightarrow{OC}$ ៖

គេមាន $\overrightarrow{OA}(0,6,0)$ , $\overrightarrow{OB}(4,2,0)$ , $\overrightarrow{OC}(2,0,5)$

គេបាន $$\overrightarrow{OA}\times\overrightarrow{OB} = \begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ 0 & 6 & 0\\ 4 & 2 & 0\end{vmatrix} = 0.\vec{i} - 0.\vec{j} - 24.\vec{k} = -24.\vec{k}$$

ដូចនេះ $(\overrightarrow{OA}\times\overrightarrow{OB}).\overrightarrow{OC} = -5.24 = -120$ ។

ទាញរកមាឌនៃចតុមុខ $OABC$ ៖

តាមរូបមន្ត $V_{OABC} = \frac{1}{6}.\left|\left(\overrightarrow{OA}\times\overrightarrow{OB}\right)\overrightarrow{OC}\right|$

ដូចនេះ $V_{OABC} = \frac{1}{6} \times 12 = 2$ ឯកតាមាឌ។

ឃ. ទាញរកចំងាយពីចំនុច $O$ ទៅប្លង់ $(ABC)$ ៖

តាង $d(O,(ABC))$ ជាចំងាយពីចំនុច $O$ ទៅប្លង់ $(ABC)$ នាំឱ្យវាជាកំពស់

នៃ ចតុមុខ $OABC$

តាមរូបមន្ត $V_{OABC} = \frac{1}{3} . S_{ABC} \times d(O(ABC))$ ។

នាំឱ្យ $d(O,(ABC)) = \frac{3.V_{OABC}}{S_{ABC}} = \frac{3.2}{3} = 2$ ឯកត្តាប្រវែង។

ង.សរសេរសមីការប្លង់ $(ABC)$ :

តាង $\vec{n}$ ជាវ៉ិចទ័រណរម៉ាល់នៃប្លង់ $(ABC)$ នាំឱ្យ

$\vec{n} = \overrightarrow{AC} \times \overrightarrow{AB} = (-2, -4, -4)$

តាមរូបមន្ត $(ABC): a(x - x_A) + b(y - y_A) + c(z - z_A) = 0$

$$(ABC): -2(x - 0) - 4(y - 6) - 4(z - 0) = 0$$
$$(ABC): x + 2y + 2z - 12 = 0$$

ដូចនេះ $(ABC): x - 2y + 2z - 1 = 0$ ។

# លំហាត់ទី២៥

ក្នុងតំរុយអរតូណរម៉ាល់ដែលមានទិសដៅវិជ្ជមាន $(0,\vec{i},\vec{j},\vec{k})$ គេអោយចំនុច

$A(0,0,2)$ ,$B(2,0,1)$ ,$C(2,2,3)$ និង $D(0,2,4)$ ។

ក.ដៅចំនុច $A,B,C$ និង $D$ រួចបង្ហាញថាចតុកោណ $ABC$ ជាប្រលេឡូក្រាម។

ខ. គណនាផលគុណវ៉ិចទរ័ $\overrightarrow{AB} \times \overrightarrow{AC}$ គណនាក្រឡាផ្ទៃប្រលេឡូក្រាម $ABC$ ។

គ.សរសេរសមីការប្លង់$(ABC)$និងសមីការប៉ារ៉ាម៉ែត្របន្ទាត់ $(L)$កែងនឹងប្លង់

$(ABC)$ត្រង់$D$។

ឃ. កំនត់កូអរដោនេនៃចំនុច $\mathbf{E}$ បើគេដឹងថា $\overrightarrow{\mathbf{AE}}=\frac{1}{2}\left(\overrightarrow{\mathbf{AB}}\times\overrightarrow{\mathbf{AC}}\right)$ ។

ង. គណនាមាឌរបស់ព្រីសត្រង់ដែលមានកំពស់ $[\mathbf{AE}]$ និងបាតជាចតុកោណ $\mathbf{ABC}$

## ដំណោះស្រាយ

ក.ដៅចំនុច $\mathbf{A,B,C}$ និង $\mathbf{D}$ រួចបង្ហាញថាចតុកោណ $\mathbf{ABC}$ ជាប្រលេឡូក្រាម ៖

$\mathbf{A(0,0,2)}$ ,$\mathbf{B(2,0,1)}$ ,$\mathbf{C(2,2,3)}$ និង $\mathbf{D(0,2,4)}$ ។

គេមាន $\overrightarrow{\mathbf{AB}}\left(x_B-x_A, y_B-y_A, z_B-z_A\right)$

និង $\overrightarrow{\mathbf{CD}}\left(x_D-x_C, y_D-y_C, z_D-z_C\right)$

នាំឱ្យ $\overrightarrow{AB}=(2,0,-1)$ និង $\overrightarrow{DC}=(2,0,-1)$

ដោយ $\overrightarrow{AB}=\overrightarrow{DC}$ ( កូអរដោនេដូចគ្នា )

ដូចនេះ ចតុកោណ A B C ជាប្រលេឡូក្រាម។



ខ.គណនាផលគុណវ៉ិចទ័រ $[\overrightarrow{AB}\times\overrightarrow{AD}]$ គណនាក្រឡាផ្ទៃប្រលេឡូក្រាម ABCD ៖

គេមាន $\overrightarrow{AB}=(2,0,-1)$ និង $\overrightarrow{AD}=(0,2,2)$

គេបាន $\overrightarrow{AB}\times\overrightarrow{AD}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ 2 & 0 & -1\\ 0 & 2 & 2\end{vmatrix}=-2.\vec{i}-4.\vec{j}+4.\vec{k}$

ដូចនេះ $\overrightarrow{AB}\times\overrightarrow{AD}=(-2,-4,4)$ ។

តាមរូបមន្តក្រឡាផ្ទៃប្រលេឡូក្រាម ABCD ៖

$S_{ABCD}=\sqrt{(-2)^2+(-4)^2+(4)^2}=6$ ( ឯកត្តាក្រឡាផ្ទៃ ) ។

គ.សមីការប្លង់$(ABC)$និងសមីការប៉ារ៉ាម៉ែត្រ$(L)$កែងនឹងប្លង់$(ABC)$ ត្រង់ D

ដោយ $ABC$ ជាប្រលេទ្បក្រាមនោះបួនចំនុច $A,B,C,D$ នៅក្នុងប្លង់តែមួយ។

តាង $\overrightarrow{n}$ ជាវ៉ិចទ័រណរម៉ាល់នៃប្លង់ $(ABC)$ នោះគេបាន

$\overrightarrow{n} = \overrightarrow{AB} \times \overrightarrow{AD} = (-2,-4,4)$

សមីការប្លង់ $(ABC)$ អាចសរសេរតាមរូបមន្ត ៖

$(ABC): a(x - x_A) + b(y - y_A) + c(z - z_A) = 0$

$(ABC): -2(x - 0) - 4(y - 0) + 4(z - 4) = 0$

$(ABC): -2x - 4y + 4z - 16 = 0$

$(ABC): -x - 2y + 2z - 8 = 0$

ម៉្យាងទៀតតាង $\overrightarrow{u}$ ជាវ៉ិចទ័រប្រាប់ទិសនៃ $(L)$ កែងនឹងប្លង់ $(ABC)$ ត្រង់ D ៖

គេបាន $\overrightarrow{u} = \overrightarrow{AB} \times \overrightarrow{AD} = (-2,-4,4)$

តាមរូបមន្ត $(L):\begin{cases} x = x_D + a\ t \\ y = y_D + b\ t \\ z = z_D + c\ t\ , t \in IR \end{cases}$

ដូចនេះ $(L):\begin{cases} x = -2t \\ y = 2 - 4t \\ z = 4 + 4t\ \ , t \in IR \end{cases}$

ឃ. កំនត់កូអរដោនេនៃចំនុច E បើគេដឹងថា $\overrightarrow{A}\ \pm E\frac{1}{2}\left(\overrightarrow{A}\ \times BA\right)$

តាង $E(x_E, y_E, z_E)$ ។ គេមាន $\overrightarrow{A}\ = (x_E, y_E, z_E - 2)$

និង $\overrightarrow{A}\ \times \overrightarrow{AB} = (Ð2,-4,4)$

ដោយ $\overrightarrow{A}\ \pm E\frac{1}{2}\left(\overrightarrow{A}\ \times BA\right)$ នាំឱ្យ $\begin{cases} x_E = -1 \\ y_E = -2 \\ z_E - 2 = 2 \end{cases}$ ឬ $\begin{cases} x_E = -1 \\ y_E = -2 \\ z_E = 4 \end{cases}$

ដូចនេះ $E(-1, -2, 4)$ ។

## លំហាត់ទី២៦

ក្នុងតំរុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $(0,\vec{i},\vec{j},\vec{k})$

( គេយកឯកតា $1cm$ នៅលើអក្ស )។

គេឱ្យបីចំនុច $A(1,-2,3)$ ,$B(3,-1,3)$ ,$C(5,1,4)$ ។

ក-កំនត់កូអរដោនេវ៉ិចទ័រ $\overrightarrow{AB}$ និង $\overrightarrow{AC}$ រួចកំនត់តំលៃកូស៊ីនូស

នៃមុំរវាងវ៉ិចទ័រពីរនេះ ។

ខ-គណនាផលគុណវ៉ិចទ័រ $\overrightarrow{AB}$ $\overrightarrow{AC}$ រួចទាញថាបីចំនុច $A,B,C$ មិនរត់ត្រង់គ្នា ។

គ-គណនាក្រឡាផ្ទៃត្រីកោណ $ABC$ ។

ឃ-កំនត់សមីការប្លង់ $(ABC)$ ។

ង-គណនាមាឌតេត្រាអែត $ABC$ ទាញរកចំងាយពីចំនុច $D$ ទៅប្លង់ $(ABC)$ ។

ដំណោះស្រាយ

ក-កំនត់កូអរដោនេវ៉ិចទរ័ $\overrightarrow{AB}$ និង $\overrightarrow{AC}$

គេមាន $A(1,-2,3)$ ,$B(3,-1,3)$ ,$C(5,1,4)$

គេបាន $\overrightarrow{AB}(2,1,0)$ និង $\overrightarrow{AC}(4,3,1)$ ។

កំនត់តំលៃកូស៊ីនូសនៃមុំរវាងវ៉ិចទរ័ $\overrightarrow{AB}$ និង $\overrightarrow{AC}$ ៖

តាមរូបមន្ត $\cos\theta = \dfrac{x_1x_2 + y_1y_2 + z_1z_2}{\sqrt{x_1^2 + y_1^2 + z_1^2}.\sqrt{x_2^2 + y_2^2 + z_2^2}}$

$$\cos\theta = \frac{8+3+0}{\sqrt{5}.\sqrt{2}} = \frac{1}{\sqrt{61}} = \frac{11\sqrt{1\ 1}}{3\ 1\quad 0}$$

ខ-គណនាផលគុណនៃវ៉ិចទរ័ $\overrightarrow{AB}\overrightarrow{AC}$ ទាញថាបីចំនុច $A,B,C$ មិនរត់ត្រង់គ្នា

គេបាន $\overrightarrow{AB}\times\overrightarrow{AC} = \begin{vmatrix} \vec{i} & \vec{j} & \vec{k}\\ 2 & 1 & 0\\ 4 & 3 & 1\end{vmatrix} = \vec{i} - 2.\vec{j} + 2.\vec{k}$

ដូចនេះ $\overrightarrow{AB}\times\overrightarrow{AC} = (1,-2,2)$ ។

ដោយ $\overrightarrow{AB}\times\overrightarrow{AC} \neq \vec{0}$ នាំឱ្យវ៉ិចទ័រ $\overrightarrow{AB}$ និង $\overrightarrow{AC}$ មិនកូលីនេអ៊ែ គ្នា

នាំឱ្យ $A,B,C$ មិនរត់ត្រង់គ្នា។

គ-គណនាក្រឡាផ្ទៃត្រីកោណ $ABC$

$$S_{ABC} = \frac{1}{2}.\left\|\overrightarrow{AB}\times\overrightarrow{AC}\right\| = \frac{1}{2}\sqrt{1+4+4} = \frac{3}{2} = 1,5$$ ( ឯកតាផ្ទៃ )

។

ឃ-កំនត់សមីការប្លង់ $(ABC)$

តាង $\vec{n}$ ជាវ៉ិចទ័រណរម៉ាល់របស់ប្លង់ $(ABC)$

គេបាន $\vec{n} = \overrightarrow{AB}\times\overrightarrow{AC} = (1,-2,2)$

តាមរូបមន្ត $(ABC): a(x-x_A)+b(y-y_A)+c(z-z_A)=0$

$$1.(x-1)-2(y+2)+2(z-3)=0$$
$$x-2y+2z-11=0$$

ដូចនេះ $(ABC): x-2y+2z-11=0$ ។

ង-គណនាមាឌតេត្រាអែត $ABCD$

តាមរូបមន្ត $V_{ABCD}=\frac{1}{6}\cdot\left|\left(\overrightarrow{AB}\times\overrightarrow{AC}\right)\cdot\overrightarrow{AD}\right|$

ដោយ $A(1,-2,3), D(2,1,1)$ នាំឱ្យ $\overrightarrow{AD}=(1,3,-2)$

ហើយ $\overrightarrow{AB}\times\overrightarrow{AC}=(1,-2,2)$

គេបាន $V_{ABCD}=\frac{1}{6}\cdot|1-6-4|=\frac{9}{6}=\frac{3}{2}=1,5$ (ឯកតាមាឌ )។

ទាញរកចំងាយពីចំនុច $D$ ទៅប្លង់ $(ABC)$ :

តាង $h$ ជាកំពស់របស់តេត្រាអែត $ABCD$ ដែលគូសចេញពីកំពូល $D$ ទៅប្លង់បាត

នាំឱ្យ $h = d(D,(ABC))$ ជាចំងាយពីចំនុច $D$ ទៅប្លង់ $(ABC)$ ។

តាមរូបមន្ត $V_{ABCD} = \frac{1}{3} S_{ABC} \times h = \frac{1}{3} . S_{ABC} \times d(D,(ABC))$

នាំឱ្យ $d(D,(ABC)) = \frac{3.V_{ABCD}}{S_{ABC}} = \frac{3.1,5}{1,5} = 3$ ( ឯកតាប្រវែង ) ។